ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ផែនការសកម្មភាព
# ស្តីពី
# ការអប់រំពហុភាសា ២០២៤-២០២៨



## អារម្ភកថា

ក្រសួងអប់រំ យុវជន និងកីឡា បានសហការជាមួយដៃគូអភិវឌ្ឍនានា រៀបចំផែនការសកម្មភាពស្តីពីការអប់រំពហុភាសា ២០២៤-២០២៨ ដើម្បីឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ ដែលធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។

ផែនការសកម្មភាពស្តីពីការអប់រំពហុភាសា ២០២៤-២០២៨ ជាផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្តកម្មវិធីអប់រំពហុភាសាស្របតាមបរិបទកម្ពុជា។ ផែនការនេះនឹងធ្វើទំនើបកម្មអប់រំ ដោយផ្សារភ្ជាប់វប្បធម៌ ទំនៀមទម្លាប់ប្រពៃណី ការផ្លាស់ប្តូរផ្នត់គំនិតយេនឌ័រ ជំរុញឱ្យសហគមន៍ជនជាតិដើមភាគតិចចូលរួមអភិវឌ្ឍសាលារៀន ការបណ្តុះបណ្តាល និងពង្រឹងគុណវុឌ្ឍិគ្រូអប់រំពហុភាសា ដើម្បីផលិតធនធានមនុស្សដែលមានសមត្ថភាពខ្ពស់ និងចូលរួមចំណែកអភិវឌ្ឍសហគមន៍ សង្គម-សេដ្ឋកិច្ច និងសមាហរណកម្មនៅថ្នាក់តំបន់ប្រកបដោយបរិយាបន្ន និងចីរភាព។

ផែនការសកម្មភាពស្តីពីការអប់រំពហុភាសា ២០២៤-២០២៨ មានគោលបំណងអភិវឌ្ឍវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទា និងគុណសម្បទារបស់ជនជាតិដើមភាគតិចតាមរយៈកម្មវិធីអប់រំពហុភាសាផ្អែកលើភាសាកំណើត ដោយមានការចូលរួមថែរក្សាភាសា និងវប្បធម៌ ទំនៀមទម្លាប់ ប្រពៃណីរបស់ជនជាតិដើមភាគតិច ដែលនាំឱ្យមានការកើនឡើងនូវលទ្ធភាព និងលទ្ធផលសិក្សាកាន់តែប្រសើរ។ ផែនការនេះមានវិសាលភាពគ្រប់ដណ្តប់នៅកម្រិតមត្តេយ្យសិក្សា បឋមសិក្សា និងអប់រំក្រៅប្រព័ន្ធ ដែលបាននិងកំពុងអនុវត្តលើភាសាព្នង ទំពួនការ៉ែត គ្រឹង ព្រៅ ចារ៉ាយ កួយ កាចក់ និងក្រោល នៅខេត្តរតនគិរី មណ្ឌលគិរី ក្រចេះ ស្ទឹងត្រែង និងខេត្តព្រះវិហារ។

ផែនការសកម្មភាពស្តីពីការអប់រំពហុភាសាមានគោលដៅរួម៖

- បង្កើនលទ្ធផលសិក្សាមូលដ្ឋានសម្រាប់សិស្សជនជាតិដើមភាគតិចតាមរយៈកម្មវិធីអប់រំពហុភាសា
- បង្កើនការចូលរួម និងភាពម្ចាស់ការរបស់សហគមន៍ក្នុងការអនុវត្តកម្មវិធីអប់រំពហុភាសា
- ពង្រឹងសមត្ថភាពគ្រូបង្រៀន និងបុគ្គលិកជំនាញក្នុងការផ្តល់កម្មវិធីអប់រំពហុភាសាប្រកបដោយគុណភាព ដែលឆ្លើយតបនឹងយេនឌ័រ និងសាលារៀនមានសុវត្ថិភាព
- ធានានិរន្តរភាពនៃកម្មវិធីអប់រំពហុភាសាតាមរយៈការធ្វើសមាហរណកម្មគោលនយោបាយ និងការគាំទ្រពីរាជរដ្ឋាភិបាល
- បង្កើត និងអនុវត្តក្របខណ្ឌពិនិត្យតាមដាននិងការវាយតម្លៃ និងការរៀនសូត្រដ៏រឹងមាំសម្រាប់កម្មវិធីអប់រំពហុភាសា

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមនិងជឿជាក់ថា អង្គភាពក្រោមឱវាទ ដៃគូអភិវឌ្ឍ និងគ្រប់អ្នកពាក់ព័ន្ធ ចូលរួមគាំទ្រ និងជំរុញការអនុវត្តផែនការសកម្មភាពស្តីពីការអប់រំពហុភាសា ២០២៤-២០២៨ ដោយរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ និងដាក់បញ្ចូលនូវសកម្មភាពជាអាទិភាព ដើម្បីសម្រេចបានគោលដៅអភិវឌ្ឍន៍ ប្រកបដោយជោគជ័យ និងប្រសិទ្ធភាពខ្ពស់។

ថ្ងៃអង្គារ ១១ កើត ខែ ចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

# មាតិកា


| | | |
|---|---|---|
| | សារតារ | ១ |
| ១ | ចក្ខុវិស័យ | ៤ |
| ២ | គោលបំណង | ៤ |
| ៣ | វិសាលភាព | ៤ |
| ៤ | គោលដៅ | ៤ |
| ៥ | យុទ្ធសាស្ត្រ | ៤ |
| ៦ | ផែនការសកម្មភាព | ៦ |
| ៧ | ការពិនិត្យតាមដានការអនុវត្តផែនការសកម្មភាព | ២០ |
| ៨ | គម្រោងចំណាយការអនុវត្តផែនការសកម្មភាព | ២០ |
| ៩ | សេចក្តីសន្និដ្ឋាន | ២១ |
| ១០ | ឧបសម្ព័ន្ធ | ២២ |
| ១០.១ | បញ្ជីពាក្យកាត់ | ២២ |
| ១០.២ | សទ្ទានុក្រម | ២៣ |
| ១០.៣ | អត្ថប្រយោជន៍ នៃការអប់រំពហុភាសា | ២៣ |
| ១០.៤ | អនុសាសន៍វាយតម្លៃផែនការសកម្មភាព ស្តីពីការអប់រំពហុភាសា | ២៥ |
| ១០.៥ | អាទិភាពទីក្រុងបាងកកសម្រាប់អនុវត្តលើការអប់រំពហុភាសាផ្អែកលើភាសាកំណើត | ២៨ |
| ១០.៦ | ស្ថិតិជនជាតិដើមភាគតិចនៅប្រទេសកម្ពុជា | ៣២ |
| ១០.៧ | គំរូអប់រំពហុភាសាសម្រាប់ការអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធនៅកម្ពុជា | ៣៣ |
| ១០.៨ | ចំណោលចំនួនសាលារៀន គ្រូ និងសិស្សអប់រំពហុភាសា | ៣៤ |


# សារតារ

ព្រះរាជាណាចក្រកម្ពុជាមានជនជាតិដើមភាគតិចដូចជា ព្នង ក្ួយ ទំពួន ចារ៉ាយ គ្រឹង ព្រៅ កាវ៉ែត ស្មៀង ក្រោល មិល កាចក់ ព័រ ខោញ ជង ស្ួយ ថ្មូន លុន ស្ទួច រដែ ខិ រអង ស្តុង ល្មឺន សំរែ និងជនជាតិដើមភាគតិចផ្សេងៗទៀត។ ជនជាតិដើមភាគតិចទាំងអស់(ប្រមាណជាង១ភាគរយនៃចំនួនប្រជាជនសរុប) រស់នៅក្នុងខេត្តមួយចំនួនដូចជា ខេត្តរតនគិរី មណ្ឌលគិរី ក្រចេះ ស្ទឹងត្រែង ព្រះវិហារ កំពង់ចាម កំពង់ធំ សៀមរាប ឧត្តរមានជ័យ ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ កំពង់ស្ពឺ កោះកុង ព្រះសីហនុ និងតំបន់ផ្សេងៗទៀត។ នៅខេត្តនៃតំបន់ខ្ពង់រាបភាគឦសានទាំង៥ (ខេត្តរតនគិរី មណ្ឌលគិរី ក្រចេះ ស្ទឹងត្រែង និងខេត្តព្រះវិហារ) មានជនជាតិដើមភាគតិចចំនួនប្រមាណជាង១០ក្រុមដែលមានប្រជាជនសរុបប្រមាណ ១៨៣ ២៨២នាក់ រួមទាំងមានកុមារអាយុពី៣ ដល់ ៥ឆ្នាំ ប្រមាណ ១៤ ៩២៥នាក់ និងមានកុមារអាយុពី ៦ ដល់១៧ឆ្នាំ ប្រមាណ ៦៧ ៥២៧នាក់ (ឧបសម្ព័ន្ធ ១០.៦)។

ជនជាតិដើមភាគតិចនៅខេត្តនៃតំបន់ខ្ពង់រាប ភាគច្រើនរស់នៅតាមភូមិដាច់ស្រយាលក្នុងកម្រិតដង់ស៊ីតេទាប ដែលមានផ្លូវគមនាគមន៍ មធ្យោបាយធ្វើដំណើរមានការលំបាក ហើយពឹងផ្អែកទាំងស្រុងទៅលើបរិស្ថានធម្មជាតិ រួមទាំងមានសេវាសុខភាព និងសេវាអប់រំតិចតួច ជាហេតុធ្វើឱ្យចំណេះដឹង និងការអប់រំរបស់ពួកគាត់នៅមានកម្រិត។

ជនជាតិដើមភាគតិចទាំងនោះប្រកាន់យកវប្បធម៌ ទំនៀមទម្លាប់ ប្រពៃណី ជំនឿ និងភាសាផ្សេងៗគ្នាទៅតាមក្រុមរបស់ខ្លួន និងមានឱកាសតិចតួចក្នុងការធ្វើទំនាក់ទំនងជាមួយសង្គមខ្មែរទូទៅ។ ការប្រើប្រាស់ភាសាផ្ទាល់ខ្លួនរបស់ក្រុមជនជាតិដើមភាគតិចនីមួយៗរបស់ពួកគាត់មានភាពខុសគ្នានឹងភាសាខ្មែរ ហើយមានតែមួយចំនួនតូចប៉ុណ្ណោះចេះនិយាយ ឬយល់ភាសាខ្មែរដែលជាភាសាជាតិផ្លូវការរបស់ប្រទេសកម្ពុជា។ នៅពេលកុមារជនជាតិដើមភាគតិចចាប់ផ្តើមចូលសាលារៀន គ្រូប្រើប្រាស់ភាសាជាតិជាភាសាមួយដែលពួកគាត់មិនយល់ ជារឿយៗកុមារជាច្រើននាក់បានប្រឡងធ្លាក់ រៀនត្រួតថ្នាក់ និងបោះបង់ការសិក្សា។ កត្តាទាំងនេះបានជំរុញឱ្យយើងទាំងអស់គ្នាចូលរួម និងយកចិត្តទុកដាក់ក្នុងការដោះស្រាយ។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៣១ ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីកិច្ចដូចគ្នាទាំងអស់ដោយឥតប្រកាន់ជាតិសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។ មាត្រា៦៧ លើកឡើងពីការអនុវត្តកម្មវិធីសិក្សា និងគោលការណ៍គរុកោសល្យទំនើប រាប់បញ្ចូលទាំងបច្ចេកវិទ្យា និងភាសាបរទេស។ មាត្រា៦៨ រដ្ឋផ្តល់ការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សានៅសាលារៀនសាធារណៈសម្រាប់ពលរដ្ឋគ្រប់រូបដោយឥតបង់ថ្លៃ ដើម្បីផ្តល់លទ្ធភាពឱ្យប្រជាពលរដ្ឋទាំងអស់ទទួលបានការអប់រំយ៉ាងតិចប្រាំបួនឆ្នាំ។

រាជរដ្ឋាភិបាលបានរៀបចំច្បាប់ស្តីពីការអប់រំ ដែលបានអនុម័តនៅឆ្នាំ២០០៧ មានគោលបំណងអភិវឌ្ឍធនធានមនុស្សដោយផ្តល់ការអប់រំពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។ មាត្រា២៤ ភាសាខ្មែរជាភាសាយាន និងជាមុខវិជ្ជាមួយនៃកម្មវិធីសិក្សាគោលនៅក្នុងសាលារៀនចំណេះទូទៅសាធារណៈ ហើយ

ភាសាសម្រាប់ប្រើប្រាស់ចំពោះអ្នកសិក្សាសញ្ជាតិខ្មែរ ដែលមានដើមកំណើតជាខ្មែរជនជាតិដើមភាគតិច ត្រូវបានកំណត់ដោយក្រសួងទទួលបន្ទុកវិស័យអប់រំ។

ឆ្នាំ១៩៩៥ ក្រសួងអប់រំ យុវជន និងកីឡា បានសហការជាមួយអង្គការសហប្រតិបត្តិការអន្តរជាតិកម្ពុជា បានចាប់ផ្តើមរៀបចំប្រព័ន្ធអក្ខរក្រមនៃភាសាជនជាតិដើមភាគតិចចំនួន៥ ក្នុងចំណោមភាសាទាំងអស់ប្រមាណ២៤ភាសា ជាភាសាដែលគេនិយាយទូលំទូលាយច្រើន ហើយយកអក្ខរក្រមខ្មែរធ្វើជាគោល និងអនុម័តនៅឆ្នាំ២០០៣ ដើម្បីសម្របសម្រួលដល់ការរៀនរបស់សិស្សជនជាតិដើមភាគតិចព្នង ទំពួន ការ៉ែត ព្រៅ និងគ្រឹង។ ក្នុងពេលជាមួយគ្នានេះដែរ អង្គការសហប្រតិបត្តិការអន្តរជាតិកម្ពុជា បានបង្កើតកម្មវិធីអក្ខរកម្មពីរភាសាដែលរៀបចំឡើងសម្រាប់ការអប់រំក្រៅប្រព័ន្ធ ដោយផ្តោតលើអក្ខរកម្មមនុស្សពេញវ័យ។

ដោយប្រើប្រាស់ក្របខណ្ឌគតិយុត្ត និងបទពិសោធដែលទទួលបានពីដៃគូអភិវឌ្ឍនានា ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតគណៈកម្មការអប់រំពីរភាសា ដើម្បីរៀបចំគោលការណ៍ណែនាំលេខ ២៩៧២ អយក.បស ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១០ ស្តីពីការអនុវត្តកម្មវិធីអប់រំពីរភាសាសម្រាប់កុមារជនជាតិដើមភាគតិចនៅក្នុងខេត្តនៃតំបន់ខ្ពង់រាប ប្រកាសលេខ ៤៨ អយក.ប្រក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៣ ស្តីពីការកំណត់ភាសាសម្រាប់អ្នកសិក្សាសញ្ជាតិខ្មែរ ដែលមានដើមកំណើតជាខ្មែរជនជាតិដើមភាគតិច និងប្រកាសលេខ ១១១៧ អយក.ប្រក ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការគ្រប់គ្រងកម្មវិធីអប់រំពហុភាសា។ ក្រសួងអប់រំ យុវជន និងកីឡា បានសហការជាមួយដៃគូអភិវឌ្ឍពាក់ព័ន្ធរៀបចំសៀវភៅសិក្សា និងគំរូអប់រំពហុភាសាពីថ្នាក់ទី១ ដល់ថ្នាក់ទី៣ នៅកម្រិតបឋមសិក្សា ដើម្បីជាស្ពានសម្រាប់ជួយកុមារជនជាតិដើមភាគតិចទៅប្រើប្រាស់ភាសាជាតិ។

ឆ្នាំ២០០២ ក្រសួងអប់រំ យុវជន និងកីឡា បានសហការជាមួយអង្គការឃែរកម្ពុជា អនុវត្តសាកល្បងគម្រោងអប់រំកុមារតំបន់ខ្ពង់រាបនៅខេត្តរតនគិរី។ ឆ្នាំ២០០៣ អង្គការឃែរកម្ពុជាបានអនុវត្តសាកល្បងកម្មវិធីអប់រំពីរភាសាក្នុងប្រព័ន្ធកម្រិតបឋមសិក្សានៅភូមិជនជាតិដើមភាគតិចទំពួន និងគ្រឹងចំនួន ៦ភូមិ នៅខេត្តរតនគិរី ហើយទទួលបានជោគជ័យដោយមានការគាំទ្រពីអង្គការយូនីសេហ្វ និងទីភ្នាក់ងារអូស្ត្រាលីដើម្បីអភិវឌ្ឍន៍អន្តរជាតិ(AusAID)។ ឆ្នាំ២០០៧ ក្រសួងអប់រំ យុវជន និងកីឡា បានសហការជាមួយអង្គការយូនីសេហ្វ អនុវត្តកម្មវិធីអប់រំពីរភាសានៅកម្រិតបឋមសិក្សា ដែលមានការគាំទ្របច្ចេកទេសពីអង្គការឃែរកម្ពុជានៅខេត្តរតនគិរី និងពង្រីកវិសាលភាពដល់ខេត្តមណ្ឌលគិរី ស្ទឹងត្រែង និងចុងក្រោយនៅខេត្តក្រចេះ។ ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៨ ក្រសួងអប់រំ យុវជន និងកីឡា បានអនុវត្តកម្មវិធីអប់រំពហុភាសាសម្រាប់បឋមសិក្សា កើនឡើងពី ៥៤សាលារៀន ដល់ ៨០សាលារៀន។

ឆ្នាំ២០០៩ អង្គការឃែរកម្ពុជាបានចាប់ផ្តើមអនុវត្តគម្រោងអប់រំពីរភាសាសាកល្បងនៅតាមសាលាមត្តេយ្យសិក្សាសហគមន៍។ នៅឆ្នាំ២០១១ នាយកដ្ឋានអប់រំកុមារតូច បានសហការជាមួយសហគមន៍ និងអាជ្ញាធរដែនដី ចាប់ផ្តើមអនុវត្តគម្រោងសាកល្បងរបស់ខ្លួនដោយបញ្ចូលមត្តេយ្យសិក្សាសហគមន៍ ២០កន្លែង នៅក្នុងខេត្តគោលដៅចំនួន ៥(ខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ក្រចេះ និងព្រះវិហារ) ជាមត្តេយ្យសិក្សាសហគមន៍អប់រំពហុភាសា ដោយមានការគាំទ្រពីអង្គការយូនីសេហ្វ និងបច្ចេកទេសពីអង្គការឃែរកម្ពុជា។ ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៨ ក្រសួងអប់រំ យុវជន និងកីឡា បានអនុវត្តកម្មវិធីអប់រំពហុភាសាសម្រាប់មត្តេយ្យសិក្សាកើនឡើងពី ៣៤ថ្នាក់/មណ្ឌល ដល់ ៩៤ថ្នាក់/មណ្ឌល។



ឆ្នាំ២០១៤ ក្រសួងអប់រំ យុវជន និងកីឡា បានកសាងផែនការសកម្មភាពជាតិស្តីពីការអប់រំពហុភាសា ២០១៥-២០១៨ ដោយបានដាក់ចេញនូវយុទ្ធសាស្ត្រសំខាន់ ៦ ដើម្បីជានាការផ្តល់សេវាអប់រំសម្រាប់កុមារជនជាតិដើមភាគតិច និងមានការវាយតម្លៃបញ្ចប់ការអនុវត្តផែនការសកម្មភាពនេះដោយបណ្ឌិត Jessica Ball និង Merriam Smith នៅចុងឆ្នាំ២០១៨។ លទ្ធផលនៃការវាយតម្លៃ បានផ្តល់បទពិសោធ និងអនុសាសន៍ដែលជាធាតុចូលសម្រាប់អភិវឌ្ឍផែនការសកម្មភាពស្តីពីការអប់រំពហុភាសា ២០១៩-២០២៣ ឱ្យកាន់តែមានសក្តានុពល ហើយបានដាក់ចេញនូវ ៣គោលដៅ និង ៧យុទ្ធសាស្ត្រ ដោយផ្តោតទៅលើការអភិវឌ្ឍបំណិនទាំង៣(វិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា) តាមរយៈការផ្តល់កម្មវិធីអប់រំពហុភាសាដោយផ្សារភ្ជាប់នឹងវប្បធម៌របស់បងប្អូនជនជាតិដើមភាគតិច ដែលនាំឱ្យមានការកើនឡើងនូវការផ្តល់សេវាពី ៩៤កន្លែង ដល់ ១៣៣កន្លែង សម្រាប់មត្តេយ្យសិក្សា លើសចំណុចដៅ ៦កន្លែង និងបានពង្រីកអនុវត្តលើភាសាចារ៉ាយនៅស្រុកអូរយ៉ាដាវ និងអណ្តូងមាស ក្នុងខេត្តរតនគិរី ដែលធ្វើឱ្យមានការកើនឡើងពី ៨០សាលារៀន ដល់ ៩៦សាលារៀន សម្រាប់បឋមសិក្សា ក្រោមចំណុចដៅ ២សាលារៀន។

ក្នុងអំឡុងពេលអនុវត្តផែនការសកម្មភាពស្តីពីការអប់រំពហុភាសា ២០១៩-២០២៣ ក៏កើតវិបត្តិនៃការរាតត្បាតជាសកលនៃជំងឺកូវីដ១៩ ក្រសួងអប់រំ យុវជន និងកីឡា នៅតែបន្តផ្តល់ការបង្រៀន និងការរៀនរបស់សិស្សថ្នាក់អប់រំពហុភាសា មានភាពបត់បែននិងច្នៃប្រឌិត ដោយផលិតឃ្លីបសំឡេងបង្រៀនពីចម្ងាយ និងចាក់ផ្សាយតាមស្ថានីយវិទ្យុ ព្រមទាំងផ្តល់សម្ភារៈសិក្សាដូចជា វិទ្យុ សន្លឹកកិច្ចការ សម្ភារៈសិក្សាកញ្ចប់អំណានតាមផ្ទះ សៀវ្វង និងសម្ភារៈអនាម័យផ្សេងៗជាច្រើនទៀត ដើម្បីធានាដល់ការរៀនសូត្ររបស់សិស្សជនជាតិដើមភាគតិចនៅតែបន្ត និងមានគុណភាព។ម្យ៉ាងវិញទៀតសាលារៀនមួយចំនួនបានចាកចេញពីកម្មវិធីអប់រំពហុភាសា ដោយយោងតាមការសម្រេចចិត្តរបស់សហគមន៍ដែលអះអាងថា ការផ្តល់សេវាអប់រំពហុភាសាកន្លងមក បានជួយពួកគាត់ពីមួយជំនាន់ទៅមួយជំនាន់អាចប្រើប្រាស់ភាសាជាតិក្នុងការប្រាស្រ័យទាក់ទងគ្នាទាំងនៅផ្ទះ សហគមន៍ ទីសាធារណៈ និងសាលារៀនកាន់តែប្រសើរឡើង ជាហេតុនាំឱ្យកុមារជនជាតិដើមភាគតិចមានលទ្ធភាពចូលរៀនថ្នាក់អប់រំបរិយាបន្នជាមួយកុមារទូទៅបានប្រសើរ។

ឆ្នាំ២០២៤ ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការវិភាគលើកម្មវិធីអប់រំពហុភាសា សម្រាប់រៀបចំ និងអភិវឌ្ឍផែនការសកម្មភាពស្តីពីការអប់រំពហុភាសា ២០២៤-២០២៨ និងបានរំលេចភាពរីកចម្រើនក្នុងការផ្តល់សេវាអប់រំប្រកបដោយសមធម៌ដល់សហគមន៍ជនជាតិដើមភាគតិចក៏ដោយ ក៏នៅតែមានបញ្ហាប្រឈមមួយចំនួនដូចជា ការបណ្តុះបណ្តាលគ្រូមិនបានគ្រប់គ្រាន់ ធនធាននៅមានកម្រិត និងពឹងផ្អែកលើមូលនិធិគាំទ្រពីខាងក្រៅ។ ផែនការសកម្មភាពស្តីពីការអប់រំពហុភាសានេះនឹងពង្រឹងលើការផ្តល់សេវាអប់រំឱ្យមានគុណភាពដោយផ្តោតលើការអភិវឌ្ឍសៀវភៅសិក្សា សម្ភារៈសិក្សា ជាពិសេសការកសាងសមត្ថភាពគ្រូបង្រៀន បុគ្គលិកអប់រំ និងអ្នកពាក់ព័ន្ធ លើការអប់រំពហុភាសា។ ជាងនេះទៅទៀតនឹងជំរុញសាលារៀន សហគមន៍ និងដៃគូអភិវឌ្ឍ ចូលរួមអភិវឌ្ឍសាលារៀន និងគាំទ្រការសិក្សារបស់កុមារ ជាពិសេសផ្តោតលើក្រុមកុមារងាយរងគ្រោះនិងកុមារមានការលំបាកប្រទាក់ក្រឡាគ្នា ទទួលបានការអប់រំប្រកបដោយសមធម៌ និងបរិយាបន្ន។

## ១- ចក្ខុវិស័យ

ផែនការសកម្មភាពស្តីពីការអប់រំពហុភាសា មានចក្ខុវិស័យអភិវឌ្ឍជនជាតិដើមភាគតិចទទួលបានការអប់រំតាមរយៈភាសាកំណើតដែលមានគុណភាព ប្រកបដោយបរិយាបន្ន សមធម៌ និងឱកាសសិក្សាពេញមួយជីវិត ដើម្បីក្លាយជាពលរដ្ឋពេញលេញ មានគុណតម្លៃ និងផលិតភាពក្នុងការចូលរួមលើកកម្ពស់ភាពចម្រុះផ្នែកភាសា និងវប្បធម៌ រួមទាំងមានសមត្ថភាពរួមចំណែកអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចប្រកបដោយចីរភាព។

## ២- គោលបំណង

ផែនការសកម្មភាពស្តីពីការអប់រំពហុភាសា មានគោលបំណងអភិវឌ្ឍវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទា និងគុណសម្បទារបស់ជនជាតិដើមភាគតិចតាមរយៈកម្មវិធីអប់រំពហុភាសាផ្អែកលើភាសាកំណើត ដោយមានការចូលរួមថែរក្សាភាសា និងវប្បធម៌ ទំនៀមទម្លាប់ ប្រពៃណីរបស់ជនជាតិដើមភាគតិច ដែលនាំឱ្យមានការកើនឡើងនូវលទ្ធភាព និងលទ្ធផលសិក្សាកាន់តែប្រសើរ។

## ៣- វិសាលភាព

កម្មវិធីអប់រំពហុភាសាមានវិសាលភាព នៅកម្រិតមត្តេយ្យសិក្សា បឋមសិក្សា និងអប់រំក្រៅប្រព័ន្ធដែលបាននិងកំពុងអនុវត្តលើភាសាព្នង ទំពួន កាវ៉ែត គ្រឹង ព្រៅ ចារ៉ាយ កួយ កាចក់ និងក្រោល នៅខេត្តរតនគិរី មណ្ឌលគិរី ក្រចេះ ស្ទឹងត្រែង និងខេត្តព្រះវិហារ។

## ៤- គោលដៅ

១- បង្កើនលទ្ធផលសិក្សាមូលដ្ឋានសម្រាប់សិស្សជនជាតិដើមភាគតិចតាមរយៈកម្មវិធីអប់រំពហុភាសា
២- បង្កើនការចូលរួម និងភាពម្ចាស់ការរបស់សហគមន៍ក្នុងការអនុវត្តកម្មវិធីអប់រំពហុភាសា
៣- ពង្រឹងសមត្ថភាពគ្រូបង្រៀន និងបុគ្គលិកជំនាញក្នុងការផ្តល់កម្មវិធីអប់រំពហុភាសាប្រកបដោយគុណភាព ដែលឆ្លើយតបនឹងយេនឌ័រ និងសាលារៀនមានសុវត្ថិភាព
៤- ធានានិរន្តរភាពនៃកម្មវិធីអប់រំពហុភាសាតាមរយៈការធ្វើសមាហរណកម្មគោលនយោបាយ និងការគាំទ្រពីរាជរដ្ឋាភិបាល
៥- បង្កើត និងអនុវត្តក្របខណ្ឌពិនិត្យតាមដាននិងការវាយតម្លៃ និងការរៀនសូត្រដ៏រឹងមាំសម្រាប់កម្មវិធីអប់រំពហុភាសា

## ៥- យុទ្ធសាស្ត្រ

១- អភិវឌ្ឍ និងចែកចាយធនធានអប់រំជាភាសាជនជាតិដើមភាគតិច ដែលពាក់ព័ន្ធនឹងវប្បធម៌ និងការផ្លាស់ប្តូរផ្នត់គំនិតយេនឌ័រ ប្រកបដោយបរិយាបន្ន
២- អនុវត្តវិធីសាស្ត្រវាយតម្លៃជាពីរភាសា ដើម្បីវាស់វែងលទ្ធផលសិក្សារបស់សិស្សឱ្យបានត្រឹមត្រូវ
៣- ផ្តល់ការគាំទ្រចំគោលដៅ ដើម្បីបង្កើនវត្តមាន និងការបន្តការសិក្សារបស់សិស្ស
៤- ពង្រឹងភាពជាដៃគូ និងកិច្ចសហការរវាងសាលារៀននិងសហគមន៍ក្នុងមូលដ្ឋាន
៥- បង្កើនការយល់ដឹងអំពីអត្ថប្រយោជន៍នៃការអប់រំពហុភាសាក្នុងចំណោមសមាជិកសហគមន៍



៦- សម្របសម្រួលការចូលរួមចំណែករបស់សហគមន៍ក្នុងកម្មវិធីអប់រំពហុភាសា ដោយធានានិងយកចិត្តទុកដាក់លើសំឡេងរបស់មាតាបិតា អ្នកថែទាំ អ្នកដឹកនាំសហគមន៍ រួមទាំងអ្នកដឹកនាំសាសនា ជនមានពិការភាព និងតុល្យភាពសំឡេងរបស់ស្ត្រីនិងបុរស យុវជននិងកុមារ
៧- ផ្តល់កម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈ និងការបណ្តុះបណ្តាលគ្រប់ជ្រុងជ្រោយដល់គ្រូបង្រៀន និងបុគ្គលិកអប់រំពហុភាសា ដោយឆ្លើយតបនឹងយេនឌ័រ
៨- ពង្រឹងយន្តការក្នុងការជ្រើសរើសគ្រូបង្រៀនអប់រំពហុភាសានៅសហគមន៍ជនជាតិដើមភាគតិច
៩- បញ្ចូលអក្ខរកម្មឌីជីថល រួមទាំងកិច្ចការពារកុមារ និងសុវត្ថិភាពតាមបណ្តាញអ៊ីនធឺណិតទៅក្នុងការបណ្តុះបណ្តាល និងការបំប៉នសមត្ថភាពគ្រូអប់រំពហុភាសា
១០- ស្វែងរកការគាំទ្រផ្នែកគោលនយោបាយ សម្រាប់ការអប់រំពហុភាសានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
១១- ធ្វើស្ថាប័នូបនីយកម្ម និងធានាប្រភពថវិកាដែលមាននិរន្តរភាពសម្រាប់កម្មវិធីអប់រំពហុភាសា
១២- បង្កើត និងអនុវត្តប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃ និងការរៀនសូត្រប្រកបដោយប្រសិទ្ធភាពដែលរួមបញ្ចូលសូចនាករបែងចែកតាមភេទ អាយុ សមត្ថភាព និងទីតាំងភូមិសាស្ត្រ

## ៦- ផែនការសកម្មភាព

| សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា(ឆ្នាំ) 1 | 2 | 3 | 4 | 5 | អង្គភាពទទួលខុសត្រូវចម្បង | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា (USD) | ការពិនិត្យតាមដាននិងវាយតម្លៃ | ប្រភពសម្រាប់ផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| គោលដៅ ១- បង្កើនលទ្ធផលសិក្សាមូលដ្ឋានសម្រាប់សិស្សជនជាតិដើមភាគតិចតាមរយៈកម្មវិធីអប់រំពហុភាសា | | | | | | | | | | | | | |
| យុទ្ធសាស្ត្រ ១.១- អភិវឌ្ឍ និងចែកចាយធនធានអប់រំជាភាសាជនជាតិដើមភាគតិច ដែលពាក់ព័ន្ធនឹងវប្បធម៌ និងការផ្លាស់ប្តូរផ្នត់គំនិតយេនឌ័រ ប្រកបដោយបរិយាបន្ន | | | | | | | | | | | | | |
| ១.១.១- ប្រជុំពិគ្រោះយោបល់វិភាគស្ថានភាពស្តីពីការកំណត់ពីតម្រូវការភាសា និងមាតិកាវប្បធម៌ពាក់ព័ន្ធ សម្រាប់អភិវឌ្ឍធនធានអប់រំពហុភាសា។ | ចំនួនកិច្ចប្រជុំដែលបានរៀបចំដើម្បីកំណត់ពីតម្រូវការភាសា | ៤ដង | | x | x | x | x | -នា.អកប<br>-មគក.សត<br>-មន្ទីរ.អយក | -នា.បស<br>-នា.អកត<br>-នា.អកស<br>-នា.គន<br>-នា.អគអ<br>-សាលារៀន<br>-ដៃគូអភិវឌ្ឍ<br>-សហគមន៍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ២ ៥០០០ | -នា.អកប<br>-មន្ទីរ.អយក<br>-មគក.សត | របាយការណ៍<br>នា.អកប<br>មគក.សត<br>មន្ទីរអយក |
| ១.១.២- អភិវឌ្ឍសម្ភារៈសិក្សាផ្សារភ្ជាប់នឹងទំនៀមទម្លាប់ប្រពៃណី ចំណេះដឹង និងបច្ចេកវិទ្យា រួមទាំងក្នុងទម្រង់ឌីជីថល ដើម្បីដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សាអប់រំពហុភាសា។ | ចំនួនសម្ភារៈសិក្សាដែលបានអភិវឌ្ឍ | យ៉ាងតិច ៤ សម្ភារៈសិក្សា | x | x | x | x | x | -នា.អកប<br>-មគក.សត<br>-មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន | -នា.បស<br>-នា.អកត<br>-នា.អកស<br>-នា.អគអ<br>-នា.កបប<br>-នា.បឧ<br>-មន្ទីរអយក<br>-ការិ.អយក<br>-ដៃគូអភិវឌ្ឍ<br>-សហគមន៍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ៣៥ ០០០ | -នា.អកប<br>-មគក.សត<br>-មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន | របាយការណ៍<br>នា.អកប<br>មគក.សត<br>មន្ទីរអយក<br>ការិ.អយក<br>សាលារៀន |



| សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា(ឆ្នាំ) 1 | 2 | 3 | 4 | 5 | អង្គភាពទទួលខុសត្រូវចម្បង | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា (USD) | ការពិនិត្យតាមដាននិងវាយតម្លៃ | ប្រភពសម្រាប់ផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១.១.៣- បង្កើតធនធានអប់រំ រួមមានទាំងវចនានុក្រមជាភាសាជនជាតិដើមភាគតិចនៅលើថ្នាលឌីជីថល ឱ្យឆ្លើយតបនឹងយេនឌ័រ និងបរិយាបន្ន ដែលអាចជួយសិស្សរៀនទាន់មេរៀនដែលខកខាន និងបន្តចូលរួមក្នុងសកម្មភាពសាលារៀន។ | ចំនួនធនធានអប់រំដែលបានបង្កើត និងផ្តល់ជូននៅលើថ្នាលឌីជីថល | ៥ធនធាន | x | x | x | x | x | -នា.អកប<br>-មគក.សត<br>-សគរ.ពហ<br>-សគរ.គ្រប<br>-មន្ទីរអយក | -នា.បស<br>-នា.អកត<br>-នា.អកស<br>-នា.បឧ<br>-មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន<br>-ដៃគូអភិវឌ្ឍ<br>-សហគមន៍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ៧០ ០០០ | -នា.អកប<br>-មគក.សត<br>-មន្ទីរអយក | របាយការណ៍<br>នា.អកប<br>មគក.សត<br>មន្ទីរអយក |
| ១.១.៤- ផ្តល់ការបណ្តុះបណ្តាល និងបំប៉នលើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដល់គ្រូបង្រៀន និងបុគ្គលិកអប់រំស្តីពីការប្រើប្រាស់ធនធានភាសាដែលពាក់ព័ន្ធនឹងវប្បធម៌របស់សហគមន៍ជនជាតិដើមភាគតិចដោយផ្តោតលើកញ្ចប់អំណានដំបូង និងកញ្ចប់គណិតវិទ្យាដំបូងប្រកបដោយប្រសិទ្ធភាព។ | ចំនួនភាគរយគ្រូបង្រៀនអប់រំពហុភាសាដែលបានទទួលការបណ្តុះបណ្តាល/បំប៉ន | ១០០% | x | x | x | x | x | -នា.អកប<br>-មគក.សត<br>-សគរ.ពហ<br>-សគរ.គ្រប<br>-មន្ទីរអយក | -នា.កបប<br>-នា.បឧ<br>-មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន<br>-ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ៥៥ ០០០ | -នា.អកប<br>-មគក.សត<br>-សគរ.ពហ<br>-សគរ.គ្រប<br>-មន្ទីរអយក | របាយការណ៍<br>នា.អកប<br>មគក.សត<br>សគរ.ពហ<br>សគរ.គ្រប<br>មន្ទីរអយក |
| ១.១.៥- ផលិតឬបកប្រែសៀវភៅរឿងជាភាសាជនជាតិដើមភាគតិច រួមទាំងដាក់បញ្ចូលទៅក្នុងថ្នាលឌីជីថលសម្រាប់កម្មវិធីអប់រំពហុភាសាកម្រិតមត្តេយ្យសិក្សា និងបឋមសិក្សា។ | ចំនួនសៀវភៅរឿងបានផលិត ឬបកប្រែជាភាសាជនជាតិដើមភាគតិច | ៥០ក្បាល | x | x | x | x | x | -នា.អកប<br>-មគក.សត<br>-មន្ទីរអយក<br>-ដៃគូអភិវឌ្ឍ | -នា.បស<br>-នា.អកត<br>-នា.អកស<br>-នា.បឧ<br>-មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន<br>-ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ៥០ ០០០ | -នា.អកប<br>-មគក.សត<br>-មន្ទីរអយក<br>-ដៃគូអភិវឌ្ឍ | របាយការណ៍<br>នា.អកប<br>មគក.សត<br>ដៃគូអភិវឌ្ឍ<br>មន្ទីរអយក |

| សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា(ឆ្នាំ) | | | | | អង្គភាពទទួលខុសត្រូវចម្បង | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា (USD) | ការពិនិត្យតាមដាននិងវាយតម្លៃ | ប្រភពសម្រាប់ផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | 1 | 2 | 3 | 4 | 5 | | | | | | |
| ១.១.៦- អភិវឌ្ឍសម្ភារៈសិក្សា និងសៀវភៅសិក្សាសម្រាប់កម្មវិធីអប់រំពហុភាសា ជាភាសាព្រៅ ពួង ការ៉ែត គ្រឹង ទំពួន និងចារ៉ាយ ដើម្បីឱ្យស្របទៅនឹងការធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាថ្នាក់ជាតិ ដោយធានាថា សម្ភារៈសិក្សាទាំងនោះផ្សារភ្ជាប់នឹងវប្បធម៌និងភាសា ឆ្លើយតបនឹងយេនឌ័រ និងបរិយាបន្ន ។ | ចំនួនសម្ភារៈសិក្សា និងសៀវភៅសិក្សាដែលបានកែសម្រួលជាភាសាជនជាតិ | យ៉ាងតិច ៥ ភាសាជនជាតិដើមភាគតិច | x | x | x | x | x | -នា.អកប<br>-មគត.សត<br>-មន្ទីរអេយក<br>-ការិ.អេយក<br>-សាលារៀន | -នា.អកស<br>-នា.បស<br>-នា.អកត<br>-នា.អធអ<br>-នា.កបប<br>-នា.បឌ<br>-សាលារៀន<br>-ដៃគូអភិវឌ្ឍ<br>-សហគមន៍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ១ ៦០០ ០០០ | -នា.អកប<br>-មគត.សត<br>-មន្ទីរអេយក<br>-ការិ.អេយក<br>-សាលារៀន | របាយការណ៍<br>នា.អកប<br>មគត.សត<br>មន្ទីរអេយក<br>ការិ.អេយក<br>សាលារៀន |
| ១.១.៧- បំប៉នសមត្ថភាពគ្រូអប់រំពហុភាសា គណៈកម្មការគ្រប់គ្រងសាលារៀន មន្ទីរអេយក និងការិ.អេយក នៃរដ្ឋបាលក្រុង ស្រុក ស្តីពីការផលិត ការប្រើប្រាស់សម្ភារៈសិក្សា និងសៀវភៅសិក្សាសម្រាប់កម្មវិធីអប់រំពហុភាសា។ | ភាគរយគ្រូអប់រំពហុភាសា និងអ្នកពាក់ព័ន្ធដែលបានបំប៉ន | ១០០% | x | x | x | x | x | -នា.អកប<br>-មន្ទីរអេយក<br>-មគត.សត | -នា. អកស<br>-នា.បស<br>-នា.អកត<br>-មន្ទីរអេយក<br>-ការិ.អេយក<br>-ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ១០០ ០០០ | -នា.អកប<br>-មន្ទីរអេយក<br>-ការិ.អេយក | របាយការណ៍<br>នា.អកប<br>មន្ទីរអេយក<br>មគត.សត |
| **យុទ្ធសាស្ត្រ ១.២- អនុវត្តវិធីសាស្ត្រវាយតម្លៃជាពីរភាសា ដើម្បីវាស់វែងលទ្ធផលសិក្សារបស់សិស្សឱ្យបានត្រឹមត្រូវ** | | | | | | | | | | | | | |
| ១.២.១- កសាងឧបករណ៍តេស្ត និងវាយតម្លៃអំណានថ្នាក់ដំបូង និងគណិតវិទ្យាដំបូង ទៅជាទម្រង់ភាសាកំណើតនិងភាសាជាតិ។ | ចំនួនកម្រិតថ្នាក់ដែលបានផលិតឧបករណ៍វាយតម្លៃ | ៣កម្រិតថ្នាក់ | | x | x | x | x | -នា.អកប<br>-មន្ទីរអេយក<br>-ការិ.អេយក<br>-សាលារៀន | -នា.អគអ<br>-នា.អកស<br>-នា.បស<br>-នា.អកត<br>-មន្ទីរអេយក<br>-ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ២៥ ០០០ | -នា.អកប<br>-មន្ទីរអេយក<br>-ការិ.អេយក<br>-សាលារៀន | របាយការណ៍<br>នា.អកប<br>មន្ទីរអេយក<br>ការិ.អេយក<br>សាលារៀន |



| សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា(ឆ្នាំ) | | | | | អង្គភាពទទួលខុសត្រូវចម្បង | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា (USD) | ការពិនិត្យតាមដាននិងវាយតម្លៃ | ប្រភពសម្រាប់ផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | 1 | 2 | 3 | 4 | 5 | | | | | | |
| ១.២.២- អនុវត្តសាកល្បង និងកែលម្អឧបករណ៍តេស្ត និងវាយតម្លៃអំណានថ្នាក់ដំបូង និងគណិតវិទ្យាដំបូងជាភាសាកំណើតនិងភាសាជាតិ។ | ចំនួនកម្រិតថ្នាក់ដែលបានផលិតឧបករណ៍វាយតម្លៃ | ៣កម្រិតថ្នាក់ | | x | x | x | x | -នា.អកប<br>-មន្ទីរអេយក<br>-ការិ.អេយក<br>-សាលារៀន | -នា.អគអ<br>-នា.បស<br>-នា.អកត<br>-មន្ទីរអេយក<br>-ការិ.អេយក<br>-ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ១៥ ០០០ | -នា.អកប<br>-មន្ទីរអេយក<br>-ការិ.អេយក<br>-សាលារៀន | របាយការណ៍<br>នា.អកប<br>មន្ទីរអេយក<br>ការិ.អេយក<br>សាលារៀន |
| ១.២.៣- បំប៉នសមត្ថភាពគ្រូបង្រៀន គណៈគ្រប់គ្រង និងអ្នកពាក់ព័ន្ធ ស្តីពីការកសាងឧបករណ៍តេស្ត និងការវាយតម្លៃអំណានថ្នាក់ដំបូង និងគណិតវិទ្យាដំបូងជាភាសាកំណើតនិងភាសាជាតិ។ | ភាគរយគ្រូបង្រៀន និងអ្នកពាក់ព័ន្ធ ដែលបានបំប៉ន | ១០០% | | x | x | x | x | -នា.អកប<br>-មន្ទីរ អេយក | -នា.អគអ<br>-នា.បស<br>-នា.អកស<br>-មន្ទីរអេយក<br>-ការិ.អេយក<br>-ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ៥០ ០០០ | -នា.អកប<br>-មន្ទីរ អេយក | របាយការណ៍<br>នា.អកប<br>មន្ទីរអេយក |
| ១.២.៤- បង្កើត និងអនុវត្តប្រព័ន្ធប្រមូលទិន្នន័យបែបបរិមាណនិងគុណភាព ដែលទាញយកលទ្ធផលសិក្សារបស់សិស្សពីការវាយតម្លៃអំណានថ្នាក់ដំបូង និងការវាយតម្លៃគណិតវិទ្យាថ្នាក់ដំបូងជាភាសាកំណើត និងភាសាជាតិ និងប្រើប្រាស់ក្របខណ្ឌSEA-PLM។ | ចំនួនប្រព័ន្ធប្រមូលទិន្នន័យដែលបានបង្កើត និងអនុវត្ត | ១ | x | | | | x | -នា.អគអ<br>-នា.អកប | -នា.អកប<br>-នា.អកស<br>-មគត. សត<br>-មន្ទីរអេយក<br>-ការិ.អេយក<br>-សាលារៀន<br>-ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ៥០ ០០០ | -នា.អកប<br>-នា. អគអ | របាយការណ៍<br>នា.អគអ<br>នា.អកប |

| សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា(ឆ្នាំ) 1 | 2 | 3 | 4 | 5 | អង្គភាពទទួលខុសត្រូវចម្បង | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា (USD) | ការពិនិត្យតាមដាននិងវាយតម្លៃ | ប្រភពសម្រាប់ផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១.២.៥- ធ្វើការសិក្សាស្រាវជ្រាវរយៈពេលខ្លី មធ្យម និងវែង ដើម្បីតាមដានវឌ្ឍនភាព និងលទ្ធផលសិក្សារបស់សិស្សអប់រំពហុភាសា ដែលជាជនជាតិដើមភាគតិចក្នុងអនុវិស័យអប់រំកុមារតូច និងបឋមសិក្សា។ | ចំនួនការសិក្សាស្រាវជ្រាវដែលបានអនុវត្ត | -២ការសិក្សា | | x | x | x | x | -នា.អកប<br>-នា.គប | -នា.អគអ<br>-នា.អកស<br>-មគក.សត<br>-មន្ទីរអេយក<br>-ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ៤០ ០០០ | -នា.អកប<br>-នា.គប | របាយការណ៍<br>នា.អកប<br>នា.គប |
| ១.២.៦- បង្កើត និងអនុវត្តតេស្តសម្រាប់ថ្នាក់អប់រំពហុភាសា ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ដែលគ្របដណ្តប់លើមុខវិជ្ជាសំខាន់ៗរួមមាន ភាសាកំណើត(L1) ភាសាជាតិ (L2) គណិតវិទ្យា វិទ្យាសាស្ត្រ និងសិក្សាសង្គម។ | ចំនួនដងដែលសាលារៀននីមួយៗបានធ្វើតេស្តស្តង់ដាក្នុងមួយឆ្នាំ | ៤ដងក្នុងមួយឆ្នាំ | | x | x | x | x | -នា.អកប<br>-នា.អគអ<br>-មន្ទីរអេយក<br>-ការិ.អេយក<br>-សាលារៀន | -នា.បស<br>-នា.អកត<br>-នា.អកស<br>-ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ៤០ ០០០ | -នា.អកប<br>-នា.អគអ<br>-មន្ទីរអេយក<br>-ការិ.អេយក<br>-សាលារៀន | របាយការណ៍<br>នា.អកប<br>នា.អគអ<br>មន្ទីរអេយក<br>ការិ.អេយក<br>សាលារៀន |
| **យុទ្ធសាស្ត្រ ១.៣- ផ្តល់ការគាំទ្រចំគោលដៅ ដើម្បីបង្កើនវត្តមាន និងការបន្តការសិក្សារបស់សិស្ស** | | | | | | | | | | | | | |
| ១.៣.១- គូស និងដៅផែនទីខ្នងផ្ទះ និងផែនទីសិក្សារបស់កុមារ និងសិស្សជនជាតិដើមភាគតិចដែលមានតម្រូវការគាំទ្រ ប្រឈមនឹងការបោះបង់ការសិក្សា ក្រីក្រ បញ្ហាសុខភាព និងកុមារងាយរងគ្រោះផ្សេងៗ។ | ភាគរយសាលារៀនដែលមានថ្នាក់អប់រំពហុភាសាបានគូស និងដៅផែនទីសិក្សា និងផែនទីខ្នងផ្ទះ | ១០០% | x | x | x | x | x | -សាលារៀន<br>-ការិ.អេយក<br>-មន្ទីរអេយក | -នា.បស<br>-នា.អកត<br>-នា.អកប<br>-ដៃគូអភិវឌ្ឍ<br>-សហគមន៍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ២៥ ០០០ | -សាលារៀន<br>-ការិ.អេយក<br>-មន្ទីរអេយក | របាយការណ៍<br>សាលារៀន<br>ការិ.អេយក<br>មន្ទីរអេយក |



| សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា(ឆ្នាំ) 1 | 2 | 3 | 4 | 5 | អង្គភាពទទួលខុសត្រូវចម្បង | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា (USD) | ការពិនិត្យតាមដាននិងវាយតម្លៃ | ប្រភពសម្រាប់ផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១.៣.២- ផ្តល់អាហារូបករណ៍ ដល់សិស្សក្រីក្រជាជនជាតិដើមភាគតិច( សម្ភារៈសិក្សា ឯកសណ្ឋាន អាហារពេលព្រឹក ការដឹកជញ្ជូនប្រកបដោយសុវត្ថិភាពដល់សិស្ស......)។ | ចំនួនភាគរយសិស្សអប់រំពហុភាសាកម្រិតបឋមសិក្សា | -យ៉ាងតិច ១៥% | x | x | x | x | x | -នា.បស<br>-នា.អកត<br>-មន្ទីរអេយក<br>-ការិ.អេយក<br>-សាលារៀន | -នា.អកប<br>-មន្ទីរអេយក<br>-ការិ.អេយក<br>-សាលារៀន<br>-ដៃគូអភិវឌ្ឍ<br>-សប្បុរសជន | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ<br>-សប្បុរសជន | ១០០ ០០០ | -នា.បស<br>-នា.អកត<br>-មន្ទីរ.អេយក<br>-ការិ.អេយក<br>-សាលារៀន<br>-ដៃគូអភិវឌ្ឍ | របាយការណ៍<br>នា.អកត<br>នា.បស<br>មន្ទីរ.អេយក<br>ការិ.អេយក<br>សាលារៀន<br>ដៃគូអភិវឌ្ឍ |
| **គោលដៅ ២- បង្កើនការចូលរួម និងភាពម្ចាស់ការរបស់សហគមន៍ក្នុងការអនុវត្តកម្មវិធីអប់រំពហុភាសា** | | | | | | | | | | | | | |
| **យុទ្ធសាស្ត្រ ២.១- ពង្រឹងភាពជាដៃគូ និងកិច្ចសហការរវាងសាលារៀន និងសហគមន៍ក្នុងមូលដ្ឋាន** | | | | | | | | | | | | | |
| ២.១.១- សិក្សាពីស្ថានភាព និងកំណត់ពីតម្រូវការភាសាជនជាតិដើមភាគតិច។ | ចំនួនការសិក្សា និងស្រាវជ្រាវពីតម្រូវការភាសា | ១ | x | x | x | x | x | -នា.អកប<br>-មគក.សត<br>-មន្ទីរអេយក<br>-ដៃគូអភិវឌ្ឍ | -នា.អកប<br>-នា.អកត<br>-នា.បស<br>-ការិ.អេយក<br>-សាលារៀន<br>-ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ២០ ០០០ | -នា.អកប<br>-មគក.សត<br>-មន្ទីរអេយក<br>-ដៃគូអភិវឌ្ឍ | របាយការណ៍<br>នា.អកប<br>មគក.សត<br>មន្ទីរអេយក<br>ដៃគូអភិវឌ្ឍ |
| ២.១.២- ចងក្រងអក្ខរក្រមភាសាជនជាតិដើមភាគតិចថ្មីៗ។ | ចំនួនភាសាជនជាតិដើមភាគតិចត្រូវបានចងក្រង | ១ | x | x | x | x | x | -នា.អកប<br>-មគក.សត<br>-ដៃគូអភិវឌ្ឍ | -នា.បស<br>-នា.អកត<br>-នា.អកស<br>-មន្ទីរអេយក<br>-ការិ.អេយក<br>-សាលារៀន<br>-ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ៤០ ០០០ | -នា.អកប<br>-មគក.សត<br>-ដៃគូអភិវឌ្ឍ | របាយការណ៍<br>នា.អកប<br>មគក.សត |

| សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា(ឆ្នាំ) | | | | | អង្គភាពទទួលខុសត្រូវចម្បង | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពថវិកា | ថវិកា (USD) | ការពិនិត្យតាមដាននិងវាយតម្លៃ | ប្រភពសម្រាប់ផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | 1 | 2 | 3 | 4 | 5 | | | | | | |
| ២.១.៣- ពង្រឹងគណៈកម្មការសហគមន៍ជនជាតិដើមភាគតិច និងអ្នកពាក់ព័ន្ធ លើការរៀបចំ ការពិនិត្យតាមដាន និងកែលម្អផែនការអភិវឌ្ឍសាលារៀននៅតាមសាលារៀន ដែលអនុវត្តថ្នាក់អប់រំពហុភាសា។ | ចំនួនកិច្ចប្រជុំដែលបានរៀបចំ ហើយមានអ្នកពាក់ព័ន្ធនិងសហគមន៍ចូលរួម | ៥ដង | x | x | x | x | x | -មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន | -នា.អកប<br>-នា.ផែនការ<br>-នា. បស<br>-នា. អកត<br>-ដៃគូអភិវឌ្ឍ<br>-សហគមន៍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ<br>-សប្បុរសជន | ២០ ០០០ | -មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន | របាយការណ៍<br>មន្ទីរអយក<br>ការិ.អយក<br>សាលារៀន |
| ២.១.៤- រៀបចំព្រឹត្តិការណ៍វប្បធម៌ដើម្បីអបអរសាទរភាសា និងប្រពៃណីជនជាតិដើមភាគតិចនៅតាមសាលារៀន និងនៅថ្នាក់ស្រុក ថ្នាក់ខេត្ត និងថ្នាក់ជាតិ រួមទាំងទិវាអន្តរជាតិជនជាតិដើមភាគតិចពិភពលោក នៅថ្ងៃទី៩ ខែសីហា ដោយផ្តោតជាពិសេសថា ព្រឹត្តិការណ៍ទាំងនេះលើកកម្ពស់សមភាពយេនឌ័រ និងមានលក្ខណៈបរិយាបន្នសម្រាប់ទាំងអស់គ្នា។ | -ចំនួនខេត្ត ស្រុក<br>-ភាគរយសាលារៀនដែលអនុវត្តថ្នាក់អប់រំពហុភាសាបានចូលរួមក្នុងព្រឹត្តិការណ៍ | -៥ខេត្ត<br>១៥ស្រុក<br>-យ៉ាងតិច<br>៥០% | x | x | x | x | x | -នា.អកប<br>-មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន<br>-ដៃគូអភិវឌ្ឍ | -នា.បស<br>-នា.អកត<br>-អាជ្ញាធរ<br>-ដៃគូអភិវឌ្ឍ<br>-សហគមន៍ | -ដៃគូអភិវឌ្ឍ<br>-សប្បុរសជន | ១៥ ០០០ | -នា.អកប<br>-មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន<br>-ដៃគូអភិវឌ្ឍ | របាយការណ៍<br>នា.អកប<br>មន្ទីរអយក<br>ការិ.អយក<br>សាលារៀន<br>ដៃគូអភិវឌ្ឍ |
| **យុទ្ធសាស្ត្រ ២.២- បង្កើនការយល់ដឹងអំពីអត្ថប្រយោជន៍នៃការអប់រំពហុភាសាក្នុងចំណោមសមាជិកសហគមន៍** | | | | | | | | | | | | | |
| ២.២.១- រៀបចំថ្ងៃបវេសនកាល ប្រជុំជាមួយសហគមន៍ និងជំនួបមាតាបិតា-គ្រូ ជាប្រចាំ ដើម្បីសង្កេតមើលថ្នាក់រៀន និងពិភាក្សាអំពីផលជះនៃការអប់រំពហុភាសាលើលទ្ធផលសិក្សារបស់សិស្ស ក៏ដូចជាបង្ហាញពីសាលារៀនបរិយាបន្ន និងមានសុវត្ថិភាពដែលលើកកម្ពស់សមភាពយេនឌ័រ។ | ភាគរយនៃសាលារៀនដែលអនុវត្តថ្នាក់អប់រំពហុភាសា | ១០០% | x | x | x | x | x | -សាលារៀន<br>-មន្ទីរអយក<br>-ការិ.អយក | -នា.អកប<br>-នា.បស<br>-នា.អកត<br>-មន្ទីរអយក<br>-ការិ.អយក<br>-សហគមន៍<br>-ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ២០ ០០០ | -សាលារៀន<br>-មន្ទីរអយក<br>-ការិ.អយក | របាយការណ៍<br>សាលារៀន<br>ការិ.អយក<br>មន្ទីរអយក |



| សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា(ឆ្នាំ) | | | | | អង្គភាពទទួលខុសត្រូវចម្បង | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពថវិកា | ថវិកា (USD) | ការពិនិត្យតាមដាននិងវាយតម្លៃ | ប្រភពសម្រាប់ផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | 1 | 2 | 3 | 4 | 5 | | | | | | |
| ២.២.២- ផលិត និងផ្សព្វផ្សាយវីដេអូស្តីពីការយល់ដឹងពីអត្ថប្រយោជន៍ការអប់រំពហុភាសា និងរៀបចំការសម្តែងសិល្បៈរបស់កុមារជនជាតិដើមភាគតិចនៅក្នុងទិវាកុមារអន្តរជាតិ ០១ មិថុនា និងព្រឹត្តិការណ៍នានា។ | -ចំនួនវីដេអូដែលបានផលិត<br>-ភាគរយសាលារៀនដែលបានរៀបចំការសម្តែងសិល្បៈ | -៥<br>-១០០% | x | x | x | x | x | -នា.អកប<br>-មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន<br>-ដៃគូអភិវឌ្ឍ | -នា.អកប<br>-នា.បស<br>-នា.អកត<br>-មន្ទីរអយក<br>-ការិ.អយក<br>-សហគមន៍<br>-ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ២០ ០០០ | -នា.អកប<br>-មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន<br>-ដៃគូអភិវឌ្ឍ | របាយការណ៍<br>នា.អកប<br>មន្ទីរអយក<br>ការិ.អយក<br>សាលារៀន<br>ដៃគូអភិវឌ្ឍ |
| **យុទ្ធសាស្ត្រ ២.៣- សម្របសម្រួលការចូលរួមចំណែករបស់សហគមន៍ក្នុងកម្មវិធីអប់រំពហុភាសា ដោយធានានិងយកចិត្តទុកដាក់លើសំឡេងរបស់មាតាបិតា អ្នកថែទាំ អ្នកដឹកនាំសហគមន៍ រួមទាំងអ្នកដឹកនាំសាសនា ជនមានពិការភាព និងតុល្យភាពសំឡេងរបស់ស្ត្រីនិងបុរស យុវជននិងកុមារ** | | | | | | | | | | | | | |
| ២.៣.១- រៀបចំប្រជុំចែករំលែកនិងផ្លាស់ប្តូរវប្បធម៌ ពិធាស់ទុំ និងសមាជិកសហគមន៍នៅតាមសាលារៀនអប់រំពហុភាសា។ | ចំនួនសាលារៀនដែលបានប្រជុំ | យ៉ាងតិច<br>៥០% | | | x | x | x | -សាលារៀន<br>-ការិ.អយក<br>-មន្ទីរអយក | -នា.អកប<br>-មន្ទីរអយក<br>-ការិ.អយក<br>-ដៃគូអភិវឌ្ឍ<br>-សហគមន៍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ១០ ០០០ | -មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន | របាយការណ៍<br>សាលារៀន<br>ការិ.អយក<br>មន្ទីរអយក |
| ២.៣.២- គាំទ្រគណៈកម្មការភាសាថ្នាក់ខេត្ត និងគណៈកម្មការគ្រប់គ្រងសាលារៀន ចូលរួមជាសមាជិកសហគមន៍ សិល្បករ អ្នកនិពន្ធ និងអ្នកនិទានរឿង ដើម្បីផលិតនិងអភិវឌ្ឍធនធានអប់រំ ដែលផ្សារភ្ជាប់នឹងវប្បធម៌ និងទំនៀមទម្លាប់ប្រពៃណី។ | ចំនួនធនធាន និងសម្ភារៈ ធនធាន ដែលគណៈកម្មការភាសាបានចូលរួម | ១០<br>ធនធាន | x | x | x | x | x | -នា.អកប<br>-មន្ទីរអយក<br>-ការិ.អយក | -នា.អកប<br>-មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន<br>-អាជ្ញាធរ<br>-ដៃគូអភិវឌ្ឍ<br>-សហគមន៍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ<br>-សប្បុរសជន | ១០ ០០០ | -នា.អកប<br>-មន្ទីរអយក<br>-ការិ.អយក | របាយការណ៍<br>នា.អកប<br>មន្ទីរអយក<br>ការិ. អយក |

| សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា(ឆ្នាំ) 1 | 2 | 3 | 4 | 5 | អង្គភាពទទួលខុសត្រូវចម្បង | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា (USD) | ការពិនិត្យតាមដាននិងវាយតម្លៃ | ប្រភពសម្រាប់ផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **គោលដៅ ៣- ពង្រឹងសមត្ថភាពគ្រូបង្រៀន និងបុគ្គលិកជំនាញក្នុងការផ្តល់កម្មវិធីអប់រំពហុភាសាប្រកបដោយគុណភាព ដែលឆ្លើយតបនឹងយេនឌ័រ និងសាលារៀនមានសុវត្ថិភាព** | | | | | | | | | | | | | |
| **យុទ្ធសាស្ត្រ ៣.១- ផ្តល់កម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈ និងបណ្តុះបណ្តាលគ្រប់ជ្រុងជ្រោយដល់គ្រូបង្រៀន និងបុគ្គលិកអប់រំពហុភាសា ដោយឆ្លើយតបនឹងយេនឌ័រ** | | | | | | | | | | | | | |
| ៣.១.១- បង្កើតកម្មវិធីអនឡាញសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (CPD) និងរៀបចំសិក្ខាសាលាកសាងសមត្ថភាពប្រចាំឆ្នាំសម្រាប់បុគ្គលិកអប់រំដែលពាក់ព័ន្ធនៅគ្រប់កម្រិត លើកម្មវិធីអប់រំពហុភាសា។ | ភាគរយនៃបុគ្គលិកអប់រំ និងអ្នកពាក់ព័ន្ធបានទទួលការកសាងសមត្ថភាព | ៨០% | x | x | x | x | x | -នា.អកប<br>-នា.បឧ<br>-មគក.សត<br>-សគវ.ក្រច<br>-សគវ.ពហ<br>-មន្ទីរអយក | -នា.អកស<br>-នា.បស<br>-នា.អកត<br>-នា.កវក<br>-មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន<br>-ដៃគូអភិវឌ្ឍ | ថវិកាកម្មវិធី<br>ដៃគូអភិវឌ្ឍ | ៣០ ០០០ | -នា.អកប<br>-នា.បឧ<br>-មគក.សត<br>-សគវ.ក្រច<br>-សគវ.ពហ<br>-មន្ទីរអយក | របាយការណ៍<br>នា.អកប<br>នា.បឧ<br>មគក.សត<br>សគវ.ក្រច<br>សគវ.ពហ<br>មន្ទីរអយក |
| ៣.១.២- បំប៉នសមត្ថភាព ស្តីពីជំនាញអភិវឌ្ឍធនធាន និងបង្កើតបណ្តាញសម្រាប់ចែករំលែកធនធាន ដល់គ្រូបង្រៀន គណៈកម្មការគ្រប់គ្រងសាលារៀន មន្ទីរអប់រំ យុវជន និងកីឡា និងការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក។ | ភាគរយនៃគ្រូបង្រៀន និងអ្នកពាក់ព័ន្ធ បានទទួលការបំប៉នសមត្ថភាព | ១០០% | | x | x | x | x | -នា.អកប<br>-មន្ទីរអយក<br>-ការិ.អយក | -នា.អកស<br>-នា.អកប<br>-មគក.សត<br>-សាលារៀន<br>-ដៃគូអភិវឌ្ឍ | ថវិកាកម្មវិធី<br>ដៃគូអភិវឌ្ឍ | ៣០ ០០០ | -នា.អកប<br>-មន្ទីរអយក<br>-ការិ.អយក | របាយការណ៍<br>មន្ទីរអយក<br>ការិ.អយក<br>នា.អកប |
| ៣.១.៣- បង្កើតក្រុមការងារអប់រំពហុភាសាតាមប្រព័ន្ធឌីជីថល និងបណ្តាញសហការ ថ្នាក់សាលារៀន ស្រុក និងខេត្ត ដើម្បីចែករំលែកវឌ្ឍនភាព បញ្ហាប្រឈម និងលើកទិសដៅការងារអប់រំពហុភាសា (សន្និសីទប្រជុំ ទស្សនកិច្ចសិក្សាផ្សេងៗ)។ | ចំនួនដងដែលបានចែករំលែកការងារអប់រំពហុភាសាតាមបណ្តាញសង្គមក្នុងមួយឆ្នាំ | ២ដងក្នុងមួយឆ្នាំ | | x | x | x | x | -នា.អបក<br>-មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន | -នា.អបក<br>-មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន<br>-សហគមន៍<br>-ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ១៥ ០០០ | -នា.អកប<br>-មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន | របាយការណ៍<br>នា.អកប<br>មន្ទីរអយក<br>ការិ.អយក<br>សាលារៀន |



| សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា(ឆ្នាំ) 1 | 2 | 3 | 4 | 5 | អង្គភាពទទួលខុសត្រូវចម្បង | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា (USD) | ការពិនិត្យតាមដាននិងវាយតម្លៃ | ប្រភពសម្រាប់ផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៣.១.៤- បង្កើតកម្មវិធី និងបំប៉នសមត្ថភាពគ្រូអប់រំពហុភាសាស្តីពីការប្រើប្រាស់ធនធានអប់រំឌីជីថល រួមទាំងការបង្កើតមាតិកា និងការប្រើប្រាស់នៅលើពហុប្រព័ន្ធផ្សព្វផ្សាយប្រកបដោយប្រសិទ្ធភាពក្នុងការបង្រៀន និងការធានាសុវត្ថិភាពដល់កុមារតាមបណ្តាញអ៊ីនធឺណិត។ | ភាគរយគ្រូអប់រំពហុភាសាដែលបានបំប៉នសមត្ថភាព | ១០០% | x | x | x | x | x | -នា.អកប<br>-មន្ទីរអយក<br>-ការិ.អយក | -នា.បស<br>-នា.សស<br>-នា.បឧ<br>-មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន<br>-ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ១០០ ០០០ | -នា.អកប<br>-មន្ទីរអយក<br>-ការិ.អយក | របាយការណ៍<br>មន្ទីរអយក<br>នា.អកប<br>ការិ.អយក |
| **យុទ្ធសាស្ត្រ ៣.២- ពង្រឹងយន្តការក្នុងការជ្រើសរើសគ្រូបង្រៀននៅសហគមន៍ជនជាតិដើមភាគតិច** | | | | | | | | | | | | | |
| ៣.២.១- ផ្តល់អាហារូបករណ៍ និងលើកទឹកចិត្តដល់គរុសិស្ស-គរុនិស្សិតជនជាតិដើមភាគតិច ដើម្បីចាប់យកអាជីពគ្រូបង្រៀន ជាពិសេសក្នុងកម្មវិធីអប់រំពហុភាសា។ | ចំនួនអាហារូបករណ៍ គរុសិស្ស និងគរុនិស្សិតដែលរៀនក្នុងកម្មវិធីអប់រំពហុភាសា | ៥០នាក់ | | x | x | x | x | -មគក.សត<br>-សគវ.ក្រច<br>-សគវ.ពហ | -នា.អកប<br>-នា.កបប<br>-មន្ទីរ អយក | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ៥០ ០០០ | -នា.អកប<br>-នា.កបប<br>-មគក.សត<br>-សគវ.ក្រច<br>-សគវ.ពហ | របាយការណ៍<br>នា.អកប<br>នា.កបប<br>មគក.សត<br>សគវ.ក្រច<br>សគវ.ពហ |
| ៣.២.២- រៀបចំលិខិតបទដ្ឋានគតិយុទ្ធ និងផ្សព្វផ្សាយអំពីលក្ខខណ្ឌជ្រើសរើសគ្រូអប់រំពហុភាសា ដើម្បីចូលរៀននៅគ្រឹះស្ថានបណ្តុះបណ្តាល។ | ចំនួនបទដ្ឋានគតិយុទ្ធក្នុងមួយឆ្នាំ | ១ | | x | x | x | x | -នា.កបប<br>-នា.កវក<br>-នា.ធម<br>-នា.អកប | -នា.អកប<br>-មន្ទីរ អយក<br>-ការិ.អយក<br>-សាលារៀន | | | -នា.កបប<br>-នា.កវក<br>-នា.ធម<br>-នា.អកប | របាយការណ៍<br>នា.កបប<br>នា.កវក<br>នា.អកប |
| ៣.២.៣- បង្កើនចំនួនគ្រូអប់រំពហុភាសាឱ្យមានវិញ្ញាបនបត្រវិជ្ជាជីវៈគ្រូអប់រំពហុភាសានៅតាមសាលារៀនគោលដៅ ដោយផ្តោតការយកចិត្តទុកដាក់លើគុណភាពយេនឌ័រ។ | ភាគរយគ្រូអប់រំពហុភាសាដែលបានទទួលការបណ្តុះបណ្តាល | ១០០% | x | x | x | x | x | -នា.អកប<br>-មគក.សត<br>-សគវ.ក្រច<br>-សគវ.ពហ | -នា.អកប<br>-នា.កបប<br>-នា.កវក | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ៤០ ០០០ | -នា. អកប<br>-មគក.សត<br>-សគវ.ក្រច<br>-សគវ.ពហ | របាយការណ៍<br>នា.អកប<br>មគក.សត<br>សគវ.ក្រច<br>សគវ.ពហ |

| សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា(ឆ្នាំ) 1 | 2 | 3 | 4 | 5 | អង្គភាពទទួលខុសត្រូវចម្បង | ស្ថាប័នផ្ដល់ការគាំទ្រ | ប្រភពថវិកា | ថវិកា (USD) | ការពិនិត្យតាមដាននិងវាយតម្លៃ | ប្រភពសម្រាប់ផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **យុទ្ធសាស្ត្រ ៣.៣- បញ្ចូលអក្ខរកម្មឌីជីថល រួមទាំងកិច្ចការពារកុមារ និងសុវត្ថិភាពតាមបណ្ដាញអ៊ីនធឺណិត ទៅក្នុងការបណ្ដុះបណ្ដាល និងការប៉ប៉នសមត្ថភាពគ្រូអប់រំពហុភាសា** | | | | | | | | | | | | | |
| ៣.៣.១- បង្កើតម៉ូឌុលអក្ខរកម្មឌីជីថលសម្រាប់ប៉ប៉នគ្រូអប់រំពហុភាសា គរុសិស្ស គរុនិស្សិត ដែលរួមបញ្ចូលសុវត្ថិភាពតាមបណ្ដាញអ៊ីនធឺណិត និងការធានាសុវត្ថិភាពកុមារ។ | ចំនួនម៉ូឌុលអក្ខរកម្មឌីជីថលដែលបានបង្កើតឡើង | ២០ម៉ូឌុល | | x | x | x | x | -នា.អកប<br>-នា.បឧ<br>-មគក.សត | -នា.បស<br>-នា.អកត<br>-សគវ.ក្រប<br>-សគវ.ពហ<br>-មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន<br>-ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ២៥ ០០០ | -នា.អកប<br>-នា.បឧ<br>-មគក.សត | របាយការណ៍<br>នា.អកប<br>នា.បឧ<br>មគក.សត |
| **គោលដៅ ៤- ធានានិរន្តរភាពនៃកម្មវិធីអប់រំពហុភាសាតាមរយៈការធ្វើសមាហរណកម្មគោលនយោបាយ និងការគាំទ្រពីរាជរដ្ឋាភិបាល** | | | | | | | | | | | | | |
| **យុទ្ធសាស្ត្រ ៤.១- ស្វែងរកការគាំទ្រផ្នែកគោលនយោបាយ សម្រាប់ការអប់រំពហុភាសានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ** | | | | | | | | | | | | | |
| ៤.១.១- រៀបចំសិក្ខាសាលាឆ្លុះបញ្ចាំងប្រចាំឆ្នាំស្ដីពីការអនុវត្តកម្មវិធីអប់រំពហុភាសា ដើម្បីចែករំលែកបទពិសោធ ដំណោះស្រាយបញ្ហាប្រឈម និងការផ្ដល់អនុសាសន៍គន្លឹះពីថ្នាក់ដឹកនាំ។ | ចំនួនសិក្ខាសាលាប្រជុំបូកសរុបក្នុងមួយឆ្នាំ | ១ដង | x | x | x | x | x | -នា.អកប<br>-មន្ទីរអយក | -នា.អកប<br>-មន្ទីរ អយក<br>-ការិ. អយក<br>-ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ៣០ ០០០ | -នា.អកប<br>-មន្ទីរអយក | របាយការណ៍<br>នា.អកប<br>មន្ទីរអយក. |
| ៤.១.២- អភិវឌ្ឍ និងផ្សព្វផ្សាយផែនការសកម្មភាព និងរៀបចំផែនការប្រចាំឆ្នាំដោយរំលេចសកម្មភាពជាអាទិភាព និងលទ្ធផលស្រាវជ្រាវថ្មីៗលើការអប់រំ ការថែរក្សាវប្បធម៌សង្គមបរិយាបន្ន និងការអប់រំប្រែកប្រែដោយការផ្លាស់ប្ដូរផ្នត់គំនិតយេនឌ័រ។ | -ចំនួនផែនការសកម្មភាព<br>-ចំនួនខេត្ត ដែលបានរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ | - ១ផែនការ<br>- ៥ខេត្ត | x | x | x | x | x | -នា.អកប<br>-មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន<br>-ដៃគូអភិវឌ្ឍ | -នា.អកប<br>-នា.បស<br>-នា.អកត<br>-នា.ផែនការ<br>-មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ២០ ០០០ | -នា.អកប<br>-មន្ទីរអយក<br>-ការិ.អយក | របាយការណ៍<br>នា.អកប<br>មន្ទីរអយក<br>ការិ.អយក |



| សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា(ឆ្នាំ) 1 | 2 | 3 | 4 | 5 | អង្គភាពទទួលខុសត្រូវចម្បង | ស្ថាប័នផ្ដល់ការគាំទ្រ | ប្រភពថវិកា | ថវិកា (USD) | ការពិនិត្យតាមដាននិងវាយតម្លៃ | ប្រភពសម្រាប់ផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **យុទ្ធសាស្ត្រ ៤.២- ធ្វើស្ថាប័នូបនីយកម្ម និងធានាប្រភពថវិកាដែលមាននិរន្តរភាពសម្រាប់កម្មវិធីអប់រំពហុភាសា** | | | | | | | | | | | | | |
| ៤.២.១- កៀរគរមូលនិធិសម្រាប់កម្មវិធីអប់រំពហុភាសា រយៈពេលខ្លី ពេលមធ្យម និងពេលវែង រួមទាំងថវិការាជរដ្ឋាភិបាល ជំនួយឧបត្ថម្ភអន្តរជាតិ ភាពជាដៃគូជាមួយវិស័យឯកជន និងការចូលរួមចំណែករបស់សហគមន៍។ | ចំនួនប្រភពថវិកា | ២ប្រភពយ៉ាងតិច | x | x | x | x | x | -នា.អកប<br>-មន្ទីរអយក<br>-ការិ.អយក | -នា. អកប<br>-នា. បស<br>-នា.ហិរញ្ញវត្ថុ<br>-នា.អកត<br>-មន្ទីរអយក<br>-ការិ.អយក | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ១០ ០០០ | -នា.អកប<br>-មន្ទីរអយក<br>-ការិ.អយក | របាយការណ៍<br>នា.អកប<br>មន្ទីរអយក<br>ការិ.អយក |
| ៤.២.២- រៀបចំឱ្យមានផាសុកវត្ថុនៃហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដោយសាងសង់ ឬជួសជុលកែលម្អអគារសិក្សា បន្ទប់ទឹក និងបណ្ណាល័យនៅមត្តេយ្យសិក្សា និងបឋមសិក្សា។ | -ចំនួនអគារមត្តេយ្យសិក្សាដែលសាងសង់ ឬជួយជុលកែលម្អ<br>-ចំនួនអគារបឋមសិក្សាដែលបានសាងសង់ ឬជួសជុលកែលម្អ<br>-ចំនួនបន្ទប់ទឹកដែលបានសាងសង់ ឬជួសជុលកែលម្អ<br>-ចំនួនបណ្ណាល័យដែលបានរៀបចំ | -មត្តេយ្យសិក្សា១០បន្ទប់<br>-បឋមសិក្សា៨អគារ<br>-១០បន្ទប់ទឹក<br>-២០បណ្ណាល័យ | x | x | x | x | x | -នា.អកប<br>-នា.ទសេណ<br>-នា.សស<br>-មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន<br>-ដៃគូអភិវឌ្ឍ | -នា.អកប<br>-នា.ទសេណ<br>-នា.បស<br>-នា.អកត<br>-នា.សស<br>-មន្ទីរអយក<br>-ការិ.អយក<br>-អាជ្ញាធរ<br>-សាលារៀន<br>-សហគមន៍<br>-ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ<br>-សប្បុរសជន | ៣ ០០០ ០០០ | -នា.អកប<br>-មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន<br>-ដៃគូអភិវឌ្ឍ | របាយការណ៍<br>នា.អកប<br>មន្ទីរអយក<br>ការិ.អយក<br>សាលារៀន<br>ដៃគូអភិវឌ្ឍ |

| សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា(ឆ្នាំ) 1 | 2 | 3 | 4 | 5 | អង្គភាពទទួលខុសត្រូវចម្បង | ស្ថាប័នផ្ដល់ការគាំទ្រ | ប្រភពថវិកា | ថវិកា (USD) | ការពិនិត្យតាមដាននិងវាយតម្លៃ | ប្រភពសម្រាប់ផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៤.២.៣- បង្កើត និងអភិវឌ្ឍមជ្ឈមណ្ឌលធនធានសម្រាប់សិក្សាស្រាវជ្រាវនិងរក្សាឯកសារធនធានការអប់រំពហុភាសា ដើម្បីលើកកម្ពស់ភាពចម្រុះនៃវប្បធម៌ និងភាសានៅកម្ពុជា។ | -ចំនួនមជ្ឈមណ្ឌលដែលបានអភិវឌ្ឍ | ១យ៉ាងតិច | x | x | x | x | x | -នា.អកប<br>-មគក.សត<br>-សគរ.ក្រច<br>-សគរ.ពហ | -នា.អកប<br>-នា.កបប<br>-នា.កវក<br>-មន្ទីរអយក<br>-ការិ.អយក<br>-ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ៤០ ០០០ | -នា.អកប<br>-មគក.សត<br>-សគរ.ក្រច<br>-សគរ.ពហ | របាយការណ៍<br>នា.អកប<br>មគក.សត<br>សគរ.ក្រច<br>សគរ.ពហ |
| ៤.២.៤- បំប៉នសមត្ថភាពស្ដីពីការអប់រំពហុភាសា ដល់បុគ្គលិកអប់រំថ្នាក់កណ្ដាល ថ្នាក់ខេត្ត និងអ្នកពាក់ព័ន្ធថ្នាក់ក្រុង ស្រុក ជាប្រចាំនៅកម្រិតមត្តេយ្យសិក្សា និងបឋមសិក្សា។ | ចំនួនអ្នកដែលបានកសាងសមត្ថភាព | ១០០នាក់ | x | x | x | x | x | -នា.អកប<br>-មន្ទីរអយក<br>-ដៃគូអភិវឌ្ឍ | -នា.អកប<br>-មគក.សត<br>-សគរ.ក្រច<br>-សគរ.ពហ<br>-មន្ទីរអយក<br>-ការិ.អយក<br>-ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ៨០ ០០០ | -នា.អកប<br>-មន្ទីរអយក<br>-ដៃគូអភិវឌ្ឍ | របាយការណ៍<br>នា.អកប<br>មន្ទីរអយក<br>ដៃគូអភិវឌ្ឍ |
| **គោលដៅ ៥- បង្កើត និងអនុវត្តក្របខណ្ឌពិនិត្យតាមដាននិងវាយតម្លៃ និងការរៀនសូត្រដ៏រឹងមាំសម្រាប់កម្មវិធីអប់រំពហុភាសា** | | | | | | | | | | | | | |
| **យុទ្ធសាស្ត្រ ៥.១- បង្កើត និងអនុវត្តប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃ និងការរៀនសូត្រប្រកបដោយប្រសិទ្ធភាពដែលរួមបញ្ចូលសូចនាករបែងចែកតាមភេទ អាយុ សមត្ថភាព និងទីតាំងភូមិសាស្ត្រ** | | | | | | | | | | | | | |
| ៥.១.១- បង្កើតក្រុមការងារអប់រំពហុភាសាថ្នាក់ខេត្ត ស្រុក និងសាលារៀន ព្រមទាំងមានការចូលរួមពីសហគមន៍ និងរៀបចំកិច្ចប្រជុំបូកសរុបការងារអប់រំពហុភាសា។ | -ចំនួនក្រុមការងារថ្នាក់ខេត្ត និងសាលារៀនដែលបានបង្កើត<br>-ចំនួនកិច្ចប្រជុំបូកសរុបថ្នាក់ខេត្ត | -៥ខេត្ត និង ៨០សាលារៀន<br>-យ៉ាងតិច១ដង/១ឆ្នាំ | | x | x | x | x | -នា.អកប<br>-មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន | -នា.អកប<br>-មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន<br>-ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ៥០ ០០០ | -នា.អកប<br>-មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន | របាយការណ៍<br>នា.អកប<br>មន្ទីរអយក<br>ការិ.អយក<br>សាលារៀន |



| សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា(ឆ្នាំ) 1 | 2 | 3 | 4 | 5 | អង្គភាពទទួលខុសត្រូវចម្បង | ស្ថាប័នផ្ដល់ការគាំទ្រ | ប្រភពថវិកា | ថវិកា (USD) | ការពិនិត្យតាមដាននិងវាយតម្លៃ | ប្រភពសម្រាប់ផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៥.១.២- អភិវឌ្ឍឧបករណ៍ពិនិត្យតាមដាន និងវាយតម្លៃសម្រាប់កម្មវិធីអប់រំពហុភាសាកម្រិតសាលារៀន និងថ្នាក់រៀន។ | ចំនួនឧបករណ៍វាយតម្លៃសម្រាប់កម្មវិធីអប់រំពហុភាសា | ២ | | x | x | x | x | -នា.អកប<br>-មន្ទីរអយក<br>-ការិ.អយក | -នា.បស<br>-នា.អគអ<br>-មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន<br>-ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ៣០ ០០០ | -នា.អកប<br>-មន្ទីរអយក<br>-ការិ.អយក | របាយការណ៍<br>នា.អកប<br>មន្ទីរអយក<br>ការិ.អយក |
| ៥.១.៣- ចុះពិនិត្យតាមដាន និងវាយតម្លៃ ឬចុះជួយគាំទ្របច្ចេកទេសការអនុវត្តកម្មវិធីអប់រំពហុភាសា។ | -ចំនួនចុះពិនិត្យតាមដាន និងវាយតម្លៃ | ២ដង/១ឆ្នាំ | x | x | x | x | x | -នា.អកប<br>-មន្ទីរអយក<br>-ការិ.អយក | -មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ១០០ ០០០ | -នា.អកប<br>-មន្ទីរអយក<br>-ការិ.អយក | របាយការណ៍<br>នា.អកប<br>មន្ទីរ អយក<br>ការិ.អយក |
| ៥.១.៤- ប្រមូលស្ថិតិ លទ្ធផលសិក្សា និងរបាយការណ៍ស្ដីពីការអប់រំពហុភាសា ដែលមានការផ្ដល់យោបល់ពីគ្រប់អ្នកពាក់ព័ន្ធថ្នាក់ខេត្ត ក្រុង ស្រុក និងសាលារៀន រួមទាំងមានការផ្ដល់មតិពីសហគមន៍ និងសិស្សានុសិស្ស។ | ចំនួនដងក្នុងមួយឆ្នាំ | ៣ | x | x | x | x | x | -នា.អកប<br>-មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន | -នា.អកប<br>-មន្ទីរអយក<br>-ការិ.អយក | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ៥ ០០០ | -នា.អកប<br>-មន្ទីរអយក | របាយការណ៍<br>នា.អកប<br>មន្ទីរអយក<br>ការិ.អយក<br>សាលារៀន |
| ៥.១.៥- ប្រជុំបូកសរុបការងារអប់រំពហុភាសាថ្នាក់ខេត្ត និងពិគ្រោះយោបល់រួមសម្រាប់កម្មវិធីអប់រំពហុភាសា។ | ចំនួនដងក្នុងមួយឆ្នាំ | ១ | x | x | x | x | x | -នា. អកប<br>-មន្ទីរអយក<br>-ការិ.អយក | -នា.អកគ<br>-នា.បស<br>-មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ៥០ ០០០ | -នា.អកប<br>-មន្ទីរអយក<br>-ការិ.អយក | របាយការណ៍<br>នា.អកប<br>មន្ទីរអយក |

## ៧- ការពិនិត្យតាមដានការអនុវត្តផែនការសកម្មភាព

ដើម្បីឱ្យផែនការសកម្មភាពស្ដីពីការអប់រំពហុភាសា ២០២៤-២០២៨ សម្រេចបានជោគជ័យ និងមានប្រសិទ្ធភាពត្រូវ៖

- បង្កើតក្រុមការងារអប់រំពហុភាសា ថ្នាក់ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ដើម្បីពិនិត្យតាមដានការអនុវត្តផែនការសកម្មភាពស្ដីពីការអប់រំពហុភាសា ២០២៤-២០២៨
- ដាក់បញ្ចូលសកម្មភាពនៃផែនការសកម្មភាពស្ដីពីការអប់រំពហុភាសា ២០២៤-២០២៨ ទៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ផែនការអភិវឌ្ឍសាលារៀន និងផែនការវិនិយោគឃុំ សង្កាត់
- ពិនិត្យតាមដានជាទៀងទាត់លើការអនុវត្តផែនការសកម្មភាពស្ដីពីការអប់រំពហុភាសា ២០២៤-២០២៨ ប្រចាំឆ្នាំ
- ប្រជុំបូកសរុបការអនុវត្តផែនការសកម្មភាពស្ដីពីការអប់រំពហុភាសា ២០២៤-២០២៨ ពាក់កណ្ដាលអណត្តិ ឆ្នាំ២០២៦
- ប្រជុំបូកសរុបបញ្ចប់ និងវាយតម្លៃការអនុវត្តផែនការសកម្មភាពស្ដីពីការអប់រំពហុភាសា ២០២៤-២០២៨ ដើម្បីពិនិត្យនូវភាពពាក់ព័ន្ធ ប្រសិទ្ធភាព ប្រសិទ្ធផល ផលជះ និងនិរន្តរភាព នៅឆ្នាំ ២០២៨
- បន្តរៀបចំ និងអភិវឌ្ឍផែនការសកម្មភាពស្ដីពីការអប់រំពហុភាសា ២០២៩-២០៣៣

## ៨- គម្រោងចំណាយការអនុវត្តផែនការសកម្មភាព

ចំណោលចំណាយសម្រាប់អនុវត្តផែនការសកម្មភាពស្ដីពីការអប់រំពហុភាសា ២០២៤-២០២៨ មានទឹកប្រាក់ចំនួន ៦ ២៤០ ០០០,០០ ដុល្លារ ដើម្បីអនុវត្តរយៈពេល ៥ឆ្នាំ លើយុទ្ធសាស្ត្រទាំង១២ និងការពិនិត្យតាមដាននិងការវាយតម្លៃផែនការសកម្មភាពស្ដីពីការអប់រំពហុភាសា ២០២៤-២០២៨៖

ខ្ទង់ចំណាយតាមយុទ្ធសាស្ត្រ

- យុទ្ធសាស្ត្រ ១.១ ៖ ១ ៩៣៥ ០០០,០០ ដុល្លារ
- យុទ្ធសាស្ត្រ ១.២ ៖ ២២០ ០០០,០០ ដុល្លារ
- យុទ្ធសាស្ត្រ ១.៣ ៖ ១២៥ ០០០,០០ ដុល្លារ
- យុទ្ធសាស្ត្រ ២.១ ៖ ៩៥ ០០០,០០ ដុល្លារ
- យុទ្ធសាស្ត្រ ២.២ ៖ ៤០ ០០០,០០ ដុល្លារ
- យុទ្ធសាស្ត្រ ២.៣ ៖ ២០ ០០០,០០ ដុល្លារ
- យុទ្ធសាស្ត្រ ៣.១ ៖ ១៧៥ ០០០,០០ ដុល្លារ
- យុទ្ធសាស្ត្រ ៣.២ ៖ ៩០ ០០០,០០ ដុល្លារ
- យុទ្ធសាស្ត្រ ៣.៣ ៖ ២៥ ០០០,០០ ដុល្លារ
- យុទ្ធសាស្ត្រ ៤.១ ៖ ៥០ ០០០,០០ ដុល្លារ



- យុទ្ធសាស្ត្រ ៤.២ ៖ ៣ ១៣០ ០០០,០០ ដុល្លារ
- យុទ្ធសាស្ត្រ ៥.១ ៖ ២៣៥ ០០០,០០ ដុល្លារ

**ទឹកប្រាក់សរុប ៖ ៦ ១៤០ ០០០,០០ ដុល្លារ**

- ការពិនិត្យតាមដាន និងវាយតម្លៃផែនការសកម្មភាព ៖ ១០០ ០០០,០០ ដុល្លារ

❖ បៀវត្ស និងប្រាក់ឧបត្ថម្ភរបស់គ្រូបង្រៀនអប់រំពហុភាសា ជាបន្ទុកចំណាយរបស់រាជរដ្ឋាភិបាល។

## ៩- សេចក្ដីសន្និដ្ឋាន

ផែនការសកម្មភាពស្ដីពីការអប់រំពហុភាសា ២០២៤-២០២៨ សម្រាប់គាំទ្រដល់ការអប់រំពហុភាសាតំបន់ខ្ពង់រាបនៃភាគឦសាននៅខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ក្រចេះ និងខេត្តព្រះវិហារ ជួយដល់កុមារជនជាតិដើមភាគតិចទទួលបានការអប់រំប្រកបដោយសមធម៌ និងបរិយាបន្ន។ ផែនការសកម្មភាពនេះនឹងជួយជំរុញក្នុងការសម្រេចគោលដៅរបស់ក្រសួងអប់រំ យុវជន និងកីឡា និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ ជាពិសេសជួយដល់ការអភិវឌ្ឍធនធានមនុស្សដោយផ្សារភ្ជាប់វប្បធម៌ និងតម្រូវការជាក់ស្ដែងរបស់សហគមន៍ជនជាតិដើមភាគតិច។

ការអនុវត្តផែនការនេះ ត្រូវពឹងផ្អែកលើធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងសម្ភារៈគាំទ្រដែលក្រសួងអប់រំ យុវជន និងកីឡា បានដាក់បញ្ចូលក្នុងផែនការសកម្មភាពស្ដីពីការអប់រំពហុភាសា ២០២៤-២០២៨ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០២៤-២០២៨ និងការចូលរួមគាំទ្រពីដៃគូអភិវឌ្ឍ គ្រប់អ្នកពាក់ព័ន្ធ និងសហគមន៍។

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមនិងជឿជាក់ថា អង្គភាពក្រោមឱវាទ ដៃគូអភិវឌ្ឍ និងគ្រប់អ្នកពាក់ព័ន្ធទាំងអស់ចូលរួមគាំទ្រ និងជំរុញការអនុវត្តផែនការសកម្មភាពស្ដីពីការអប់រំពហុភាសា ២០២៤-២០២៨ ដោយរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ ដាក់បញ្ចូលនូវសកម្មភាពជាអាទិភាព ដើម្បីសម្រេចតាមគោលដៅយុទ្ធសាស្ត្រ និងសកម្មភាពនៃផែនការនេះប្រកបដោយជោគជ័យ និងប្រសិទ្ធភាពខ្ពស់។

## ១០- ឧបសម្ព័ន្ធ

### ១០.១- បញ្ជីពាក្យកាត់

| | | |
|---|---|---|
| ការិ.អយក | : | ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក |
| នា.ពគអ | : | នាយកដ្ឋានព័ត៌មានគ្រប់គ្រងអប់រំ |
| នា.គនប | : | នាយកដ្ឋានគោលនយោបាយ |
| នា. អគអ | : | នាយកដ្ឋានអធិការកិច្ចគុណភាពអប់រំ |
| នា. ធម | : | នាយកដ្ឋានធនធានមនុស្ស |
| នា. កបប | : | នាយកដ្ឋានកិច្ចការបណ្តុះបណ្តាល |
| នា. កវក | : | នាយកដ្ឋានកិច្ចការវិក្រឹតការ |
| នា. បស | : | នាយកដ្ឋានបឋមសិក្សា |
| នា. ផក | : | នាយកដ្ឋានផែនការ |
| នា. មចទ | : | នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ |
| នា.ទរសណ | : | នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងសំណង់ |
| នា. សស | : | នាយកដ្ឋានសុខភាពសិក្សា |
| នា. អកត | : | នាយកដ្ឋានអប់រំកុមារតូច |
| នា. អកប | : | នាយកដ្ឋានអប់រំក្រៅប្រព័ន្ធនិងបរិយាបន្ន |
| នា. អកស | : | នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា |
| នា.បឌ | : | នាយកដ្ឋានបរិវត្តកម្មឌីជីថល |
| បស | : | បឋមសិក្សា |
| មតស | : | មត្តេយ្យសិក្សា |
| មគភ.សត | : | មជ្ឈមណ្ឌលគរុកោសល្យភូមិភាគឦសានខេត្តស្ទឹងត្រែង |
| មន្ទីរអយក | : | មន្ទីរអប់រំ យុវជន និងកីឡាខេត្ត |
| សគវខ.ពហ | : | សាលាគរុកោសល្យ និងវិក្រឹតការខេត្តព្រះវិហារ |
| សគវខ.ក្រច | : | សាលាគរុកោសល្យ និងវិក្រឹតការខេត្តក្រចេះ |
| សគមម | : | សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈឹម |
| អកប | : | អប់រំក្រៅប្រព័ន្ធ |



### ១០.២- សន្ទានុក្រម

ការអប់រំពហុភាសាជាការបង្រៀនអក្ខរកម្មដំបូង(ការអាន ការសរសេរ និងការគិតលេខ) ជាភាសាកំណើត(L1) ដោយមានការបង្រៀនជាភាសាទី២បន្ថែម រួមជាមួយការប្រើវិធីសាស្ត្រសមស្របក្នុងការផ្ទេរចំណេះដឹងអក្ខរកម្មពីភាសាកំណើត(L1) ទៅភាសាទី២(L2) និងផ្លាស់ប្តូរជាលំដាប់ពីភាសាកំណើតដែលជាភាសាប្រើក្នុងការបង្រៀនទៅជាការប្រើប្រាស់ភាសាកំណើត(L1)និងភាសាទី២(L2) តាមរយៈវិធីសាស្ត្រអប់រំពហុភាសា។ វិធីសាស្ត្រនេះជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់អក្ខរកម្ម និងជំនាញនៃការយល់ដឹងនៅក្នុងភាសាកំណើតដែលអាចផ្ទេរទៅភាសាទី២បាន។

កម្មវិធីអប់រំពហុភាសាផ្តោតលើការជួយដល់សិស្សានុសិស្ស ក្នុងការកសាងមូលដ្ឋានគ្រឹះដ៏រឹងមាំជាភាសាកំណើត(ភាសាទី១) ហើយប្រើជាស្ពានក្នុងការរៀនភាសាជាតិ(ភាសាទី២) ភាសាកំណើតត្រូវបានកំណត់ជាភាសាដែលបុគ្គលម្នាក់ៗចេះមុនគេ ហើយកំណត់អត្តសញ្ញាណជាមួយការដឹងប្រសើរបំផុត ប្រើច្រើនបំផុត ចេះនិយាយ និងយល់គ្រប់គ្រាន់ដើម្បីរៀននូវខ្លឹមសារដែលសមស្របតាមកម្រិតអាយុ។

ជនជាតិដើមភាគតិចគឺជាជនជាតិដែលរស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ហើយជនទាំងនោះបង្ហាញនូវឯកភាពជាតិពន្ធុ សង្គម វប្បធម៌ និងសេដ្ឋកិច្ច ប្រតិបត្តិរបៀបរស់នៅតាមបែបប្រពៃណី និងការដាំដុះលើដីដែលខ្លួនកាន់កាប់ទៅតាមក្បួនខ្នាត ទំនៀមទម្លាប់នៃការប្រើប្រាស់ដីជាសមូហភាព។
*(គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច ទំព័រទី១ សម័យប្រជុំពេញអង្គនាថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៩)*

ភាសាជាតិ សំដៅដល់ភាសាដែលប្រើជាផ្លូវការក្នុងព្រះរាជាណាចក្រកម្ពុជា។

ភាសាទី១ គឺជាភាសាកំណើតរបស់ជនជាតិ ដែលបានប្រើប្រាស់សម្រាប់ប្រាស្រ័យទាក់ទងជាប្រចាំនៅក្នុងគ្រួសារដែលយល់ន័យច្បាស់លាស់។

ភាសាទី២ គឺជាភាសាដែលមិនមែនជាភាសាកំណើត និងប្រើប្រាស់សម្រាប់ប្រាស្រ័យទាក់ទងពីជនជាតិមួយទៅជនជាតិមួយទៀត សម្រាប់កម្មវិធីអប់រំពហុភាសាភាសាទី២គឺភាសាខ្មែរ។

មត្តេយ្យសិក្សាសហគមន៍ សំដៅដល់មណ្ឌល ឬថ្នាក់មត្តេយ្យសិក្សានៅតាមឃុំ សង្កាត់ ដែលបង្កើតឡើងដោយរដ្ឋបាលឃុំ សង្កាត់ និងប្រើប្រាស់មូលនិធិរបស់ឃុំ សង្កាត់ ឬបានទទួលការគាំទ្រពីដៃគូអភិវឌ្ឍ ឬសប្បុរសជននានា។

### ១០.៣- អត្ថប្រយោជន៍ នៃការអប់រំពហុភាសា

នៅក្នុងកម្មវិធីអប់រំពហុភាសាដែលមានប្រសិទ្ធភាព សិស្សនឹងមានសមត្ថភាពក្នុងការទំនាក់ទំនងដោយប្រើភាសាទី២បានយ៉ាងល្អដូចភាសាកំណើតដែរ ហើយអាចអាន សរសេរ និងរៀនជាភាសាទាំងពីរទៀតផង។ ចាប់ផ្តើមពីការរៀនភាសាកំណើត ជាភាសាដែលពួកគាត់ចេះច្បាស់បំផុតនឹងជួយកសាងគ្រឹះដ៏រឹងមាំដែលអាចជួយឱ្យពួកគាត់ផ្ទេរទៅភាសាទី២យ៉ាងមានប្រសិទ្ធភាព។

ភស្តុតាងបានបង្ហាញថា កុមាររៀនសូត្របានល្អបំផុតនៅពេលពួកគាត់ប្រើអ្វីដែលពួកគាត់បានដឹងរួចហើយ(ចំណេះដឹង បទពិសោធ និងភាសារបស់ពួកគាត់) ដើម្បីរៀនពីអ្វីដែលថ្មី(ការពិត គំនិត និងភាសាថ្មីៗ)។ កុមារដែលមានគ្រឹះដ៏រឹងមាំនៅក្នុងភាសាកំណើត ពួកគាត់នឹងអភិវឌ្ឍសមត្ថភាពអក្ខរកម្មកាន់តែខ្លាំងនៅក្នុងភាសាទី២។

- កម្មវិធីអប់រំពហុភាសាត្រូវបានអនុវត្តដោយជោគជ័យនៅជុំវិញពិភពលោកនៅក្នុងប្រទេសជាច្រើន ភស្តុតាងពីការសិក្សាស្រាវជ្រាវបានគាំទ្រដល់សេចក្តីសន្និដ្ឋានដូចខាងក្រោម៖
  - ភាសាកំណើត(L1)របស់កុមារ មានសារៈសំខាន់ណាស់ក្នុងការអភិវឌ្ឍជំនាញមុនអក្ខរកម្ម ការបង្កើតអត្តសញ្ញាណ ការផ្សារភ្ជាប់ទៅនឹងចំណេះដឹង និងបទពិសោធដែលមានស្រាប់
  - សិស្សអប់រំពហុភាសាអភិវឌ្ឍជំនាញអក្ខរកម្មបានយ៉ាងងាយស្រួលក្នុងភាសាដែលពួកគាត់ស្គាល់ច្បាស់នឹងនាំឱ្យមានអត្រាអក្ខរកម្មខ្ពស់
  - សិស្សអប់រំពហុភាសាអភិវឌ្ឍជំនាញការយល់ដឹង និងមានការយល់ដឹងពីខ្លឹមសារមេរៀនកាន់តែប្រសើរឡើងនៅពេលបង្រៀនពួកគាត់ដោយប្រើភាសាដែលពួកគាត់ចេះស្ទាត់ និងបានផ្តល់ឱកាសស្មើគ្នាដើម្បីរៀនគ្រប់មុខវិជ្ជាដែលបង្រៀននៅតាមសាលារៀន
  - ការប្រើប្រាស់ភាសាកំណើតជួយពង្រឹងភាពក្លាហាន ភាពជឿជាក់លើខ្លួនឯង និងអត្តសញ្ញាណរបស់ពួកគាត់ដែលនាំឱ្យមានការកើនឡើងនូវការលើកទឹកចិត្ត ការចូលរួម និងការបង្កើតថ្មី
  - ការអប់រំដែលផ្តោតលើភាសាកំណើតនាំឱ្យមានភាពប្រសើរឡើងក្នុងការចូលរៀន មានការថយចុះនូវការរៀនត្រួតថ្នាក់ និងការបោះបង់ចោលការសិក្សា ក៏ដូចជាលើកកម្ពស់សមភាពយេនឌ័រ
  - ភាសា និងវប្បធម៌របស់ជនជាតិដើមភាគតិចត្រូវបានពង្រឹង គ្រូជនជាតិដើមភាគតិចដែលត្រូវបានបណ្តុះបណ្តាលទទួលបានការងារជាគ្រូបង្រៀននៅបឋមសិក្សា និងជាគ្រូសហគមន៍មត្តេយ្យសិក្សា
  - ឪពុកម្តាយនិងសហគមន៍ជនជាតិដើមភាគតិច ចូលរួមអភិវឌ្ឍកម្មវិធីសិក្សាអប់រំពហុភាសារបស់កូនៗ ការរៀនសូត្ររបស់សិស្សអាចត្រូវបានវាយតម្លៃយ៉ាងត្រឹមត្រូវ នៅពេលដែលពួកគាត់អាចបញ្ជាក់ពីខ្លួនឯងបាន នេះក៏អាចជួយឱ្យគ្រូបង្រៀនធ្វើការវិភាគលើអ្វីដែលសិស្សបានរៀនរួចហើយ អ្វីដែលត្រូវបង្រៀនពួកគាត់ ហើយសិស្សណាដែលត្រូវការជំនួយបន្ថែម
  - សិស្សនឹងចេះអក្ខរកម្មពីរភាសា និយាយ អាន និងសរសេរបានច្រើនជាងមួយភាសា
  - កម្មវិធីសិក្សាអប់រំពហុភាសាផ្អែកលើវប្បធម៌របស់សហគមន៍ជនជាតិដើមភាគតិច ដែលជាអ្នកជំនាញក្នុងវប្បធម៌របស់ពួកគាត់ ដោយប្រើចំណេះដឹងមូលដ្ឋាន និងការអនុវត្តដែលធ្វើឱ្យអ្នកសិក្សាអភិវឌ្ឍគោលគំនិតជាមូលដ្ឋានគ្រឹះលើគ្រប់ផ្នែកទាំងអស់នៃការរៀនសូត្រ

- ការគាំទ្រដល់ការអប់រំពហុភាសាដែលមានគុណភាពល្អគឺផ្តោតលើ
  - ភាពជាម្ចាស់ ភាពពាក់ព័ន្ធ និងការចូលរួមរបស់សហគមន៍
  - គ្រូបង្រៀនដែលបានបណ្តុះបណ្តាលមានជំនាញ និងសមត្ថភាពក្នុងការអភិវឌ្ឍភាសាកំណើត វិធីសាស្ត្រអប់រំពហុភាសា និងមានការយល់ដឹងពីយេនឌ័រ
  - ការអភិវឌ្ឍកម្មវិធីសិក្សា និងសម្ភារៈសិក្សាដែលទូលំទូលាយ និងសមស្របតាមវប្បធម៌
  - ភាពជាដៃគូអន្តរភ្នាក់ងារ
  - ការវាយតម្លៃសមស្របដែលឆ្លុះបញ្ចាំងពីបទពិសោធនៃការអប់រំពហុភាសា



- ភស្តុតាងជាច្រើនជុំវិញការអប់រំពហុភាសាបានបង្ហាញពីអត្ថប្រយោជន៍សំខាន់មួយចំនួនដូចជា
  - សម្រាប់កុមារជនជាតិដើមភាគតិច ពួកគាត់នឹងចូលរួមក្នុងការសិក្សាច្រើនជាងមុនឆ្លើយតបសំណួររបស់លោកគ្រូ អ្នកគ្រូ និងចូលរួមបានស្មើភាពគ្នា
  - សម្រាប់ឪពុកម្តាយជាជនជាតិដើមភាគតិច ពួកគាត់អាចចូលរួមក្នុងការសិក្សារបស់កូនៗគាំទ្រដល់គ្រូបង្រៀន និងចូលរួមក្នុងសកម្មភាពនានារបស់សាលារៀន
  - សម្រាប់សហគមន៍ជនជាតិដើមភាគតិច ពួកគាត់អាចថែរក្សាបាននូវភាសា និងអត្តសញ្ញាណវប្បធម៌ផ្ទាល់ខ្លួនរបស់ពួកគាត់ នៅពេលដែលពួកគាត់ចូលរួមយ៉ាងសកម្មជាមួយវប្បធម៌ផ្សេងទៀតនៃមនុស្សភាគច្រើន
  - សម្រាប់ការសិក្សា នឹងមានលទ្ធផលសិក្សាប្រសើរឡើង អត្រាបោះបង់ការសិក្សាមានការធ្លាក់ចុះ និងកម្រិតនៃភាពស្ទាត់ជំនាញខ្ពស់ជាងមុនសម្រាប់ភាសាទាំងពីរ គឺភាសាកំណើតរបស់អ្នកសិក្សា និងភាសាផ្លូវការផ្សេងៗទៀត
  - សម្រាប់ប្រព័ន្ធអប់រំ ការសិក្សាដែលប្រសើរឡើងមានន័យថាមានការប្រើប្រាស់ធនធានយ៉ាងមានប្រសិទ្ធផលដែលនាំឱ្យមានការសន្សំសំចៃពេលវេលា(គ្រូបង្រៀន និងរដ្ឋបាល) និងថវិកាទាំងរយៈពេលមធ្យម និងរយៈពេលវែង
  - សម្រាប់ជីវភាពរស់នៅ ការសិក្សាពិតប្រាកដ និងជំនាញភាសាដែលប្រសើរមានន័យថាទទួលបានឱកាសការងារ និងសហគមន៍ដែលមានសន្តិភាពជាងមុន

ភស្តុតាងក៏បានបង្ហាញផងដែរ ថាការចេះច្រើនជាងមួយភាសា គឺជាធនធានដែលនាំឱ្យមានសមិទ្ធិផលខ្ពស់ជាងមុននៅក្នុងកម្មវិធីសិក្សាទាំងអស់ និងជាការប្រើប្រាស់ធនធានមនុស្សកាន់តែប្រសើរឡើងសម្រាប់វិស័យសេដ្ឋកិច្ចរបស់ប្រទេស។ ម្យ៉ាងវិញទៀតការចេះភាសាច្រើនជាងមួយភាសាជំរុញឱ្យមានការគោរពខ្លួនឯង មានអត្តសញ្ញាណខ្លួនឯង និងមានអាកប្បកិរិយាជាវិជ្ជមានចំពោះការសិក្សារៀនសូត្រ និងនាំឱ្យមានសុខដុមរមនា និងភាពពេញចិត្តក្នុងសង្គមកាន់តែច្រើនឡើង។

## ១០.៤- អនុសាសន៍វាយតម្លៃផែនការសកម្មភាព ស្តីពីការអប់រំពហុភាសា

- ផែនការសកម្មភាពជាតិ ស្តីពីការអប់រំពហុភាសា២០១៥-២០១៨

ផែនការសកម្មភាពជាតិស្តីពីការអប់រំពហុភាសា ២០១៥-២០១៨ បានដាក់ចេញនូវគោលបំណង៤សំខាន់ៗ (១)ដើម្បីធានាយ៉ាងណាឱ្យកុមារាកុមារីជនជាតិដើមភាគតិច អាចទទួលបានការអប់រំប្រកបដោយគុណភាព និងឆ្លើយតបទៅនឹងការអប់រំសម្រាប់ទាំងអស់គ្នា (២)ដើម្បីកសាងសមត្ថភាពរបស់មន្ត្រីអប់រំនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង និងពិនិត្យតាមដានការអនុវត្តការអប់រំពហុភាសា (៣)ដើម្បីពង្រីកការផ្តល់ការអប់រំពហុភាសានៅតាមខេត្តពាក់ព័ន្ធ (៤)ដើម្បីលើកកម្ពស់គុណភាពនៃការអប់រំពហុភាសាតាមរយៈគណៈកម្មការទ្រទ្រង់សាលារៀន មាតាបិតា និងអាជ្ញាធរមូលដ្ឋាន។ ផែនការនេះមានយុទ្ធសាស្ត្រចំនួន០៦សម្រាប់អនុវត្ត (១)ការកសាងសមត្ថភាពជាពិសេសដល់គ្រូ និងការបណ្តុះបណ្តាលគ្រូ (២)ផ្តល់សម្ភារៈបង្រៀននិងរៀន (៣)ការសម្របសម្រួលទិន្នន័យ និងព័ត៌មាន ការពិនិត្យ

តាមដាន និងវាយតម្លៃ (៤)ការពង្រីកការផ្តល់សេវាអប់រំពហុភាសា (៥)ហេដ្ឋារចនាសម្ព័ន្ធ និងធនធាន (៦)សាលារៀនសហគមន៍

### អនុសាសន៍វាយតម្លៃផែនការសកម្មភាពជាតិស្តីពីការអប់រំពហុភាសា ២០១៥-២០១៨

ក្រសួងអប់រំ យុវជន និងកីឡា ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍ សហការជាមួយនឹងអ្នកទទួលបន្ទុកនៅថ្នាក់កណ្តាល ថ្នាក់ខេត្ត ស្ថាប័នសិក្សាស្រាវជ្រាវ អាជ្ញាធរមូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល និងអ្នកកាន់សិទ្ធិចម្បងដូចជា អង្គការជាជនជាតិដើមភាគតិច កុមារ និងមាតាបិតាជាដើម៖

- បន្តរៀបចំផែនការសកម្មភាពស្តីពីការអប់រំពហុភាសា ២០១៩-២០២៣ ដោយដាក់ចេញនូវយុទ្ធសាស្ត្រ និងសកម្មភាពដែលមានការប៉ាន់ប្រមាណចំណាយច្បាស់លាស់ និងកំណត់ពីគណនេយ្យភាព ការរៀបចំរបាយការណ៍ និងការវាយតម្លៃ។ ពង្រីកផែនការសកម្មភាពនេះបន្តិចម្តងៗ ដើម្បីបញ្ចូលភាសាជនជាតិដើមភាគតិចបន្ថែម
- ពង្រឹងសមត្ថភាពប្រព័ន្ធ និងស្ថាប័នរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីអនុវត្តផែនការនេះ រួមទាំងជ្រើសរើសបុគ្គលិកជនជាតិដើមភាគតិចបន្ថែមទៀត ដើម្បីបម្រើការងារនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងផ្តល់ការអភិវឌ្ឍសមត្ថភាពនាយកដ្ឋានអប់រំពិសេស និងរៀបចំរចនាសម្ព័ន្ធឱ្យបានសកម្មក្រោមការដឹកនាំរបស់មន្ត្រីជាន់ខ្ពស់នៃក្រសួងអប់រំ យុវជន និងកីឡា ដើម្បីធានាឱ្យមានកិច្ចសហការអន្តរនាយកដ្ឋាន
- បង្កើនគុណភាពមត្តេយ្យសិក្សាអប់រំពហុភាសា និងសុខដុមនីយកម្មការអប់រំពហុភាសានៅកម្រិតមត្តេយ្យសិក្សា ដោយផ្តល់ការគាំទ្រដល់មត្តេយ្យសិក្សាសហគមន៍អប់រំពហុភាសា ដើម្បីបំពេញលក្ខណៈវិនិច្ឆ័យជាមត្តេយ្យសិក្សាសហគមន៍ស្តង់ដា ដូចមានចែងក្នុងអនុក្រឹត្យលេខ ២៤៥ អនក្រ.បក ស្តីពីការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍
- បង្កើនគុណភាព បរិមាណ និងការរក្សាភាពគង់វង្សនៃគ្រូបង្រៀនដែលធ្វើការងារនៅតាមសាលាអប់រំពហុភាសា គ្រូឧទ្ទេសជនជាតិដើមភាគតិចតាមរយៈការបង្កើនការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសដល់អ្នកដែលមានភារកិច្ចត្រូវបំពេញនៅថ្នាក់ក្រោមជាតិ សម្រាប់រៀបចំការបណ្តុះបណ្តាល និងកិច្ចសហការជាមួយដៃគូអភិវឌ្ឍពាក់ព័ន្ធនឹងជនជាតិដើមភាគតិច។ ត្រៀមរៀបចំសាលាគរុកោសល្យខេត្ត ដើម្បីឱ្យសាលាទាំងនេះអាចផ្តល់ការគាំទ្រដល់គ្រូជនជាតិដើមភាគតិចក្នុងការអនុវត្តការងារអប់រំពហុភាសា
- ពិនិត្យឡើងវិញ និងបន្តកម្មវិធីសិក្សា និងធនធានសម្រាប់ការអប់រំពហុភាសា ដើម្បីធ្វើឱ្យកម្មវិធីសិក្សានេះកាន់តែមានភាពប្រសើរជាងមុន និងបន្ថែមខ្លឹមសារពាក់ព័ន្ធនឹងវប្បធម៌ឱ្យកាន់តែមានលក្ខណៈសម្បូរបែប បញ្ចូលធនធានដែលរៀបចំដោយអង្គការមិនមែនរដ្ឋាភិបាល និងជំរុញឱ្យមានការចូលរួមពីកុមារ សមាជិកសហគមន៍ និងដៃគូអភិវឌ្ឍពាក់ព័ន្ធនឹងជនជាតិដើមភាគតិច
- បង្កើនការយល់ដឹងអំពីសិទ្ធិកុមារ និងគុណតម្លៃសង្គមនៃផែនការសម្មភាពស្តីពីការអប់រំពហុភាសាតាមរយៈយុទ្ធនាការបង្កើនការយល់ដឹងជាសាធារណៈ និងពង្រឹងការស្វែងយល់ពីទស្សនទាននេះតាមរយៈការបណ្តុះបណ្តាលដល់គ្រូបង្រៀន គ្រូឧទ្ទេស និងមន្ត្រីទទួលបន្ទុកជាជនជាតិដើមភាគតិចជាអាទិភាព
- កែលម្អប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ដូចជាការបែងចែកទិន្នន័យ តាមយេនឌ័រ ជាតិពន្ធុ និងភាសា និងភាគបែងដែលពាក់ពន្ធ័ ដើម្បីកំណត់ពីវិសាលភាពប្រមូលទិន្នន័យតាមប្រព័ន្ធឌីជីថល និងទម្រង់របាយការណ៍ដែលមានលក្ខណៈស្តង់ដា
- បង្កើតភាពជាដៃគូរវាងសាកលវិទ្យាល័យក្នុងស្រុកនិងអន្តរជាតិ ដើម្បីរៀបចំតេស្តលទ្ធផលសិក្សា ដោយប្រើប្រាស់ភាសាជនជាតិដើមភាគតិច សិក្សាពីការអនុវត្តដែលមានសក្តានុពលដូចជាការពង្រីកការអប់រំពហុភាសាដល់សិស្សថ្នាក់ទី៦ និងវាយតម្លៃលទ្ធផលត្រឡប់នៃការអប់រំពហុភាសា។

### ផែនការសកម្មភាពស្តីពីការអប់រំពហុភាសា ២០១៩-២០២៣

ផែនការសកម្មភាពស្តីពីការអប់រំពហុភាសា ២០១៩-២០២៣ មានគោលបំណងអភិវឌ្ឍវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទារបស់ជនជាតិដើមភាគតិចតាមរយៈកម្មវិធីអប់រំពហុភាសា ដែលនាំឱ្យមានការកើនឡើងនូវលទ្ធភាព និងលទ្ធផលសិក្សាដោយមានការចូលរួមថែរក្សាភាសា និងវប្បធម៌របស់ជនជាតិដើមភាគតិច ហើយមាន៣គោលដៅគឺ (១)ពង្រីកសេវាអប់រំពហុភាសាប្រកបដោយសមធម៌ បរិយាបន្ន និងមាននិរន្តរភាពដល់ជនជាតិដើមភាគតិចជាពិសេសកុមារ (២)ពង្រឹងការអប់រំពហុភាសាឱ្យមានគុណភាពដោយផ្សារភ្ជាប់នឹងភាសាកំណើត វប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់របស់ជនជាតិដើមភាគតិច (៣)លើកកម្ពស់ការចូលរួមរបស់សហគមន៍ជនជាតិដើមភាគតិច និងកិច្ចសហប្រតិបត្តិការគ្រប់ភាគីពាក់ព័ន្ធ និង៧យុទ្ធសាស្ត្រគឺ (១)ផ្តល់ការគាំទ្របន្ថែមដល់ការអនុវត្ត និងពង្រីកកម្មវិធីអប់រំពហុភាសាដល់កុមារា កុមារី និងយុវជនក្រៅសាលារៀនជាជនជាតិដើមភាគតិច (២)លើកកម្ពស់សមត្ថភាពស្ថាប័នពាក់ព័ន្ធនិងអភិវឌ្ឍធនធានមនុស្សក្នុងការផ្តល់សេវាអប់រំពហុភាសាប្រកបដោយគុណភាព (៣)អភិវឌ្ឍកម្មវិធីសិក្សាអប់រំពហុភាសា និងសម្ភារៈសិក្សាដោយផ្សារភ្ជាប់នឹងវប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់របស់ជនជាតិដើមភាគតិច (៤)អភិវឌ្ឍ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធ សម្ភារៈសិក្សារូបវន្ត និងបរិស្ថានសាលារៀន (៥)ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធព័ត៌មានគ្រប់គ្រងកម្មវិធីអប់រំពហុភាសា (៦)បង្កើនការចូលរួមរបស់ឪពុកម្តាយ សហគមន៍ជនជាតិដើមភាគតិច និងកិច្ចសហការជាមួយភាគីពាក់ព័ន្ធ ដើម្បីអនុវត្តកម្មវិធីអប់រំពហុភាសា (៧)ពង្រឹងយន្តការពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស និងគុណភាពបង្រៀន និងរៀន។

## ១០.៥- អាទិភាពទីក្រុងបាងកកសម្រាប់អនុវត្តលើការអប់រំពហុភាសា ផ្អែកលើភាសាកំណើត

### I.ផ្នែកទី១- បុព្វកថា

១- **យើង** ក្នុងនាមជារដ្ឋមន្ត្រី និងជាប្រតិភូតំណាងរដ្ឋមន្ត្រី បានជួបប្រជុំនៅទីក្រុងបាងកក ប្រទេសថៃ ក្នុងវេទិកាគោលនយោបាយជាន់ខ្ពស់លើកទី៤ ស្តីពីការអប់រំពហុភាសា នាថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២៣ ទន្ទឹមនឹងសន្និសីទអន្តរជាតិលើកទី៧ ស្តីពីភាសា និងការអប់រំ ដែលបានរៀបចំឡើងចាប់ពីថ្ងៃទី០៤ ដល់ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២៣ ដើម្បីពិភាក្សាស្វែងយល់ពីតួនាទីនៃភាសាក្នុងការពន្លឿនការសិក្សា និងការពង្រឹងប្រព័ន្ធអប់រំឱ្យកាន់តែមានបរិវត្តកម្ម បរិយាបន្ន និងភាពធន់បន្ថែមទៀត។

២- **យើង សូមរំឭកឡើងវិញ** ពីសេចក្តីថ្លែងការណ៍ទីក្រុងបាងកក ស្តីពីភាសា និងបរិយាបន្ន (២០១៩) បានដាក់ចេញឯកសារលទ្ធផលនៃវេទិកាគោលនយោបាយជាន់ខ្ពស់លើកទី៣ ស្តីពីការអប់រំពហុភាសា កាលពីថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩ បានផ្តល់អនុសាសន៍លើសកម្មភាពសម្រាប់អនុវត្តឆ្ពោះទៅសម្រេចបាននូវអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ(CRC) ក្នុងការទទួលបានសិទ្ធិអប់រំប្រកបដោយគុណភាព និងគោលដៅអភិវឌ្ឍប្រកបដោយចីរភាពទី៤(SDG4) ដើម្បី"ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា" ដែលទាក់ទងនឹងភាសា ជាពិសេសនៅឆ្នាំដំបូងៗនៃការសិក្សា។

៣- **យើង សូមបញ្ជាក់ថា** របៀបកំណត់អត្តសញ្ញាណ និងប្រភេទភាសាទាំងឡាយត្រូវប្រែប្រួលទៅតាមបរិបទនៃប្រទេស។ នៅទីនេះភាសាទីមួយសំដៅទៅលើ "ភាសាដែលកុមារនិយាយ និងយល់ន័យយ៉ាងស្ទាត់ជំនាញ"។ ក្នុងឯកសារនេះ និងឯកសារផ្សេងទៀត ភាសាទីមួយ(L1) ក៏សំដៅទៅលើភាសានិយាយនៅផ្ទះ ភាសាកំណើត ឬភាសាតំបន់...។ លើសពីនេះទៅទៀត កុមារខ្លះធំឡើងនៅក្នុងសហគមន៍ពហុភាសា អាចមានភាសាកំណើតច្រើនលើសពីមួយភាសា។

៤- **យើង ទទួលស្គាល់ថា** ពិភពលោកយើងកំពុងប្រឈមមុខនឹងវិបត្តិនៃការសិក្សាមូលដ្ឋានគ្រឹះ ហើយជំងឺរាតត្បាតសកលកូវីដ១៩ ព្រមទាំងវិបត្តិ និងគ្រោះអាសន្នផ្សេងៗទៀត ដែលធ្វើឱ្យវិបត្តិនេះកាន់តែធ្ងន់ធ្ងរឡើង។ តាមការប៉ាន់ប្រមាណចិតសិបភាគរយ(៧០%) នៃកុមារអាយុ១០ឆ្នាំនៅក្នុងប្រទេសដែលមានប្រាក់ចំណូលទាប និងប្រាក់ចំណូលមធ្យម មិនអាចអាននិងយល់ពីអត្ថបទសាមញ្ញ ដូចបានសង្កត់ធ្ងន់ក្នុងកិច្ចប្រជុំកំពូលស្តីពីបរិវត្តកម្មអប់រំ កាលពីខែកញ្ញា ឆ្នាំ២០២២ កន្លងមក។

៥- **យើង កត់សម្គាល់ឃើញថា** កាលានុវត្តភាពនៃការអប់រំពហុភាសាផ្អែកលើភាសាកំណើតបានលើកកម្ពស់ការសិក្សាជាមូលដ្ឋានគ្រឹះរបស់បរិវត្តកម្មប្រព័ន្ធអប់រំ និងការរួមចំណែកជាវិជ្ជមានដល់បញ្ហាសកលដែលកំពុងតែកើតមានឡើង ដូចជាការប្រើប្រាស់ប្រព័ន្ធឌីជីថលសម្រាប់ការអប់រំ និងការអប់រំបៃតង ជា



ពិសេសសម្រាប់ក្រុមភាសាតូចៗដែលងាយរងគ្រោះដូចជាក្រុមជនជាតិភាគតិច ជនជាតិដើមភាគតិច ជនមានពិការភាព និងជនចំណាកស្រុក ឬជនភៀសខ្លួនជាដើម។

៦- **យើង រំឭកឡើងវិញ** នូវភស្តុតាងពីតំបន់អាស៊ីប៉ាស៊ីហ្វិក និងតំបន់ដទៃទៀត រួមទាំងការរាយការណ៍នៅក្នុងឯកសារបោះពុម្ពផ្សាយនៃសន្និសីទអន្តរជាតិស្តីពីភាសា និងការអប់រំ របស់ក្រុមការងារអប់រំពហុភាសាប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិកជាបន្តបន្ទាប់ ដែលបានបង្ហាញឱ្យឃើញពីផលប៉ះពាល់ជាវិជ្ជមានថា គោលនយោបាយ និងកម្មវិធីអប់រំពហុភាសាផ្អែកលើភាសាកំណើតដែលមានការរៀបចំផែនការយ៉ាងល្អ និងប្រកបដោយគុណភាព បានបង្កើនឱ្យកាន់តែប្រសើរឡើងនូវលទ្ធផលសិក្សាជាមូលដ្ឋានគ្រឹះផ្នែកភាសា និងមុខវិជ្ជាផ្សេងៗទៀត ហើយបានរួមចំណែកដល់ការអភិវឌ្ឍពេញលេញរបស់កុមារ។

៧- **យើង សង្កត់ធ្ងន់** លើតម្រូវការបន្ទាន់ឱ្យមានគោលនយោបាយ កម្មវិធី និងការអនុវត្តការអប់រំពហុភាសាផ្អែកលើភាសាកំណើត ដើម្បីពន្លឿនការសិក្សា ពង្រឹងប្រព័ន្ធអប់រំ និងដោះស្រាយវិបត្តិនៃការសិក្សាតាមរយៈភាសាកំណើត។

### II. ផ្នែកទី២- តំបន់អាទិភាពសម្រាប់សកម្មភាពនៃការអប់រំពហុភាសាផ្អែកលើភាសាកំណើត

៨- **យើង កំណត់ផ្តល់** អាទិភាពសកម្មភាពនៅក្នុងតំបន់មួយចំនួនដូចខាងក្រោម ដើម្បីពង្រឹងបន្ថែមទៅលើផែនការសកម្មភាពដែលមានចែងក្នុងផ្នែកទី៣ នៃសេចក្តីថ្លែងការណ៍ទីក្រុងបាងកក ស្តីពីភាសា និងបរិយាបន្ន(២០១៩) ហើយអំពាវនាវដល់សហគមន៍អន្តរជាតិ តំបន់ និងសហគមន៍ជាតិរបស់យើង រួមទាំងមន្ត្រីរដ្ឋាភិបាល តំណាងទីភ្នាក់ងារអង្គការសហប្រជាជាតិ ដៃគូអភិវឌ្ឍ និងអង្គការសង្គមស៊ីវិល សមាជិកស្រាវជ្រាវ យុវជន ក្រុមជាតិពន្ធុដែលប្រើភាសាជនជាតិភាគតិច និងសហគមន៍ជនជាតិដើមភាគតិចនានា ដើម្បីលើកកម្ពស់ភាសាបន្ថែមទៀតនៅក្នុងគោលនយោបាយការសិក្សា និងបរិវត្តកម្មប្រព័ន្ធអប់រំ៖

ក- យើង **សូមបញ្ជាក់ជាថ្មីឡើងវិញ** ពីសារៈសំខាន់នៃបញ្ហាភាសារៀន និងបង្រៀនតាមរយៈការស្រាវជ្រាវ គោលនយោបាយ និងការអនុវត្តពាក់ព័ន្ធផ្សេងៗ ហើយយើងទាមទារឱ្យមានវិធានការទៅលើ៖

- ការពង្រឹងការស្រាវជ្រាវដែលមានគុណភាពខ្ពស់ និងភស្តុតាងដែលបានបង្កើតឡើងនៅថ្នាក់ជាតិពីតំបន់អាស៊ីប៉ាស៊ីហ្វិក ស្តីពីភាសាដែលអ្នកសិក្សានិយាយ និងយល់ន័យយ៉ាងស្ទាត់ជំនាញតាមរយៈការរៀបចំផែនទីភាសានៅកម្រិតសាលារៀន និងតំណភ្ជាប់រវាងគោលនយោបាយ កម្មវិធី ការអនុវត្ត ព្រមទាំងការសិក្សាកម្មវិធីអប់រំពហុភាសាផ្អែកលើភាសាកំណើត ជាពិសេសអក្ខរកម្មជាមូលដ្ឋាន ជំនាញគណនា និងជំនាញដែលអាចផ្ទេរបាន រួមទាំងបញ្ហាសកលដែលកំពុងកើតមានឡើងដូចជា បញ្ហាបច្ចេកវិទ្យា និងបម្រែបម្រួលអាកាសធាតុជាដើម។

ខ- យើង **សូមបញ្ជាក់ជាថ្មីឡើងវិញ** អំពីសារៈសំខាន់នៃការជំរុញការវិនិយោគ សម្រាប់ការអប់រំពហុភាសាប្រកបដោយគុណភាពតាមរយៈការពង្រឹងការកសាងផែនការ ការពិនិត្យតាមដាន និងការផ្តល់ហិរញ្ញប្បទានប្រកបដោយសមធម៌ ហើយយើងទាមទារឱ្យមានវិធានការទៅលើ៖

- ការដាក់បញ្ចូលជាប្រព័ន្ធនូវការអប់រំពហុភាសាផ្អែកលើភាសាកំណើត ជាប្រធានបទចម្បងមួយក្នុងការពិនិត្យឡើងវិញនូវវិស័យអប់រំ ការវិភាគ និងដំណើរការកសាងផែនការ ព្រមទាំងការពិភាក្សាគោលនយោបាយដោយមានការបែងចែកថវិកាដែលមានគោលដៅ លក្ខណៈគ្រប់គ្រាន់ និងនិរន្តរភាព។

គ- យើង **សូមបញ្ជាក់ជាថ្មីឡើងវិញ** ពីសារៈសំខាន់ការលើកកម្ពស់គុណភាពនៃការអប់រំពហុភាសាផ្អែកលើភាសាកំណើតតាមរយៈការបង្កើតគោលនយោបាយ យុទ្ធសាស្រ្ត និងគោលការណ៍ណែនាំច្បាស់លាស់ផ្សេងៗ ហើយយើងទាមទារឱ្យមានវិធានការទៅលើ៖

- ការអភិវឌ្ឍ ការពិនិត្យ ការវាយតម្លៃ និងការធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាព និងការអនុវត្តគោលនយោបាយការអប់រំពហុភាសាផ្អែកលើភាសាកំណើត រួមទាំងគោលនយោបាយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីជួយឱ្យការសិក្សាជាមូលដ្ឋានគ្រឹះកើតឡើងបានក្នុងភាសា ដែលអ្នកសិក្សាម្នាក់ៗនិយាយ និងយល់ន័យយ៉ាងស្ទាត់ជំនាញនៅឆ្នាំដំបូង ដោយបន្តការណែនាំជាប្រព័ន្ធនូវភាសាផ្សេងៗ( ភាសាថ្នាក់តំបន់ ភាសាជាតិ និងភាសាអន្តរជាតិ ) នៅពេលដែលកំពុងតែរក្សាសមាសភាគភាសាកំណើតឱ្យបានយូរអង្វែងតាមដែលអាចធ្វើទៅបាន។
- ការអភិវឌ្ឍសម្ភារៈបង្រៀននិងរៀនប្រកបដោយគុណភាពខ្ពស់ដែលសមស្របនឹងវប្បធម៌ និងភាសា សម្រាប់ការបោះពុម្ព និងជាទម្រង់ឌីជីថល ព្រមទាំងការវាយតម្លៃតាមដំណាក់កាលនិងតាមសរុប ផ្អែកតាមមូលដ្ឋានកម្រិតថ្នាក់រៀនត្រូវបានរៀបចំ ដើម្បីធ្វើការពិនិត្យតាមដានលទ្ធផលសិក្សារបស់អ្នកសិក្សាពហុភាសា។
- ការធានាឱ្យមានជម្រើស និងមធ្យោបាយចម្រុះនៃការសម្របសម្រួល ការគាំទ្រ ការទទួលបាន និងការចូលរួមក្នុងដំណើរការសិក្សា រួមទាំងសម្រាប់អ្នកសិក្សានៅក្រៅសាលារៀន យុវជន និងមនុស្សពេញវ័យ នៅពេលដែលភាសាត្រូវបានគេរកឃើញថាជាឧបសគ្គសម្រាប់អ្នកសិក្សាទាំងឡាយ ក្រៅពីការអប់រំពហុភាសាផ្អែកលើភាសាកំណើតមិនទាន់មាននៅឡើយ។

ឃ- យើង **សូមបញ្ជាក់ជាថ្មីឡើងវិញ** ពីសារៈសំខាន់នៃការធ្វើពិពិធកម្មកម្លាំងពលកម្មគ្រូបង្រៀន និងការកសាងសមត្ថភាពគ្រូបង្រៀនតាមរយៈគោលនយោបាយអភិវឌ្ឍគ្រូបង្រៀន យុទ្ធសាស្រ្ត និងគោលការណ៍ណែនាំច្បាស់លាស់ ហើយយើងទាមទារឱ្យមានវិធានការទៅលើ៖

- ការបន្ស៊ីការជ្រើសរើស ការបណ្តុះបណ្តាល និងការដាក់ពង្រាយគ្រូបង្រៀនស្របទៅនឹងតម្រូវការរបស់អ្នកសិក្សាអប់រំពហុភាសា ដើម្បីធានាថាអ្នកសិក្សាទាំងនោះមានគ្រូបង្រៀនដែលអាចចែករំលែកភាសាកំណើតដូចគ្នាបាន ឬជាគ្រូបង្រៀនដែលទទួលបានការបណ្តុះបណ្តាលផ្នែកវិធីសាស្រ្តបង្រៀន និងការសិក្សាផ្អែកលើភាសាកំណើត និងការអប់រំពហុភាសា។

ង- យើង **សូមបញ្ជាក់ជាថ្មីឡើងវិញ** ពីសារៈសំខាន់នៃការប្រមូល ការពិនិត្យតាមដាន និងការរាយការណ៍នូវទិន្នន័យដែលបានបែងចែកតាមភាសាកំណើត ភ្ជាប់ទំនាក់ទំនងទៅនឹងវត្តមានតាមសាលារៀន និងលទ្ធផលសិក្សារបស់កុមារក្នុងវ័យបឋមសិក្សា (SDG សូចនាករតាមវិស័យ ៤.៥.២) ហើយយើងទាមទារឱ្យមានវិធានការទៅលើ៖

- ការពិនិត្យឡើងវិញ ការធ្វើឱ្យប្រសើរឡើង និងវិភាគទិន្នន័យជាតិ និងសូចនាករ ដើម្បីតាមដានពីទំនាក់ទំនងផ្សេងៗរវាងភាសា និងការសិក្សាស្តីពីសូចនាករគោលដៅអភិវឌ្ឍប្រកបដោយចីរភាព (SDG) ដែលពាក់ព័ន្ធទៅនឹងការសិក្សាជាមូលដ្ឋានគ្រឹះ រួមមានគោលដៅ ៤.៦.១ ៤.៦.២ និង ៤.៦.៣ ដោយមានការផ្តោតទៅលើគោលដៅ ៤.៥.២ ដែលរួមចំណែកទៅលើការវិភាគ និងដំណើរការនៃការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ និងចុងអាណត្តិនៅថ្នាក់ជាតិ និងថ្នាក់តំបន់នៃគោលដៅអភិវឌ្ឍប្រកបដោយចីរភាពទី៤(SDG4)។

ច- យើង **សូមបញ្ជាក់ជាថ្មីឡើងវិញ** ពីសារៈសំខាន់នៃការពង្រឹងភាពជាដៃគូជាមួយភាគីពាក់ព័ន្ធ និងដៃគូពាក់ព័ន្ធ ហើយយើងទាមទារឱ្យមានវិធានការទៅលើ៖

- ការជំរុញការចូលរួមរបស់ភាគីពាក់ព័ន្ធទាំងអស់ក្នុងដំណើរការកសាងផែនការ និងការអនុវត្តការអប់រំពហុភាសាផ្អែកលើភាសាកំណើត ដើម្បីធានាថាការសម្រេចចិត្តគឺផ្អែកលើភស្តុតាង និងមានលក្ខណៈសមស្របទៅនឹងបរិបទជាក់លាក់។
- ការលើកកម្ពស់តម្លៃនៃភាសា វប្បធម៌ និងចំណេះដឹងក្នុងមូលដ្ឋានជាមួយសហគមន៍ជនជាតិដើមភាគតិច និងជនជាតិភាគតិចក្នុងការការពារចំណេះដឹងក្នុងមូលដ្ឋាន ការកសាងភាពធន់ និងការអភិវឌ្ឍការសិក្សាចិត្ត-សង្គម(SEL) គ្រប់វិស័យដែលរួមចំណែកដល់ការរៀនសូត្រពេញមួយជីវិតសម្រាប់សហគមន៍ទាំងមូល។

## III. ផ្នែកទី៣- ការអប់រំពហុភាសាផ្អែកលើភាសាកំណើតជាការពន្លឿនការសិក្សាៈមធ្យោបាយឆ្ពោះទៅមុខ

៩- **យើង** នឹងយកអាទិភាពទាំងនេះ ដើម្បីអនុវត្តជាក្របខណ្ឌមួយសម្រាប់ការពន្លឿនការងារថ្នាក់ជាតិរបស់យើងក្នុងការដោះស្រាយវិបត្តិនៃការសិក្សា ការធ្វើឱ្យសម្រេចបាននូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាពទី៤(SDG4) និងការធ្វើបរិវត្តកម្មប្រព័ន្ធអប់រំឱ្យកាន់តែមានលក្ខណៈបរិយាបន្ន និងភាពធន់បន្ថែមទៀត ហើយព្រមព្រៀងធ្វើការដើម្បីជំរុញសកម្មភាពអាទិភាពទាំងនេះឱ្យទៅមុខបានដោយពិចារណាលើអាទិភាពថ្នាក់ជាតិ និងបញ្ហាប្រឈមដាច់ដោយឡែកមួយចំនួនរបស់ប្រទេសនីមួយៗ និងពិនិត្យតាមដាន

និងរាយការណ៍ពីវឌ្ឍនភាពរបស់យើងដែលប្រឆាំងទៅនឹងក្របខណ្ឌនេះនៅក្នុងព្រឹត្តិការណ៍ផ្សេងៗនាពេលអនាគត។

១០- **យើង** ស្នើសុំឱ្យក្រុមការងារអប់រំពហុភាសាអាស៊ីប៉ាស៊ីហ្វិក ដែលមានសហប្រធានដោយការិយាល័យប្រចាំតំបន់របស់អង្គការយូណេស្កូនៅទីក្រុងបាងកក និងការិយាល័យរបស់អង្គការយូនីសេហ្វប្រចាំតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ធ្វើការដើម្បីតាមដានវឌ្ឍនភាពលើសកម្មភាពអាទិភាពទាំងនេះ និងគាំទ្រដល់ប្រទេសទាំងឡាយក្នុងការអនុវត្តនូវតំបន់អាទិភាពផ្សេងៗ ដែលបានកំណត់តាមរយៈការពិនិត្យតាមដានវឌ្ឍនភាព ការកំណត់ និងផ្តល់កាលានុវត្តភាពសម្រាប់ការសិក្សា និងការអភិវឌ្ឍសមត្ថភាព ការលើកកម្ពស់ឱ្យមានការពិភាក្សាគោលនយោបាយ ឆ្លងដែន ការផ្លាស់ប្តូរ និងការរៀនសូត្រ ព្រមទាំងការសម្របសម្រួលលើការប្រមូលភស្តុតាង និងការលើកកម្ពស់ការតស៊ូមតិ ដើម្បីជួយដល់បរិវត្តកម្មប្រព័ន្ធអប់រំ ដោយមានការអប់រំពហុភាសាផ្អែកលើភាសាកំណើត។

**កំណត់សម្គាល់ការបកប្រែ៖** សម្រាប់ភាពខុសគ្នារវាងការបកប្រែសំណៅឯកសារនេះ និងសំណៅឯកសារដើមជាភាសាអង់គ្លេស ត្រូវយកសំណៅឯកសារដើមជាភាសាអង់គ្លេសគឺជាគោល។

**ការបកប្រែជាភាសាខ្មែរ៖** [ក្រសួងអប់រំ យុវជន និងកីឡា]។

## ១០.៦- ស្ថិតិជនជាតិដើមភាគតិចនៅប្រទេសកម្ពុជា

| ខេត្ត | ចំនួនប៉ាន់ស្មានប្រជាជនជនជាតិដើមភាគតិច | ចំនួនប៉ាន់ស្មាននៃកុមារជនជាតិដើមភាគតិច(៣-៥ឆ្នាំ) | ចំនួនប៉ាន់ស្មាននៃកុមារជនជាតិដើមភាគតិច (៦-១៧ឆ្នាំ) |
|---|---|---|---|
| រតនគិរី | ១១៧ ១២៩ | ៧ ៣៩៦ | ៣៥ ៧៤៣ |
| មណ្ឌលគិរី | ៤១ ៩៦៤ | ៣ ០២១ | ១៣ ២៦៣ |
| ស្ទឹងត្រែង | ៤ ៩១២ | ៧១៨ | ៣ ១២៧ |
| ក្រចេះ | ១៣ ១៤១ | ៣ ៧៩០ | ១៥ ៣៩៤ |
| ព្រះវិហារ | ៦ ១៣៦ | | |
| សរុប | ១៨៣ ២៨២ | ១៤ ៩២៥ | ៦៧ ៥២៧ |

** * *ដកស្រង់ចេញពីផែនការសកម្មភាពជាតិស្តីពីការអប់រំពហុភាសាឆ្នាំ ២០១៥-២០១៨( ទំព័រទី២១ ២៤ និងទី២៥)*



## ១០.៧- គំរូអប់រំពហុភាសាសម្រាប់ការអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធនៅកម្ពុជា

### គំរូអប់រំពហុភាសាសម្រាប់ការអប់រំក្នុងប្រព័ន្ធសម្រាប់មត្តេយ្យសិក្សា និងបឋមសិក្សា

| | | |
|---|---|---|
| **កម្រិតបឋមសិក្សា** | | |
| ថ្នាក់ទី៤ ដល់ទី៦ | ភាសាខ្មែរ ១០០% | |
| ថ្នាក់ទី៣ | ភាសាកំណើត (L1) ៣០%<br>- សិក្សាសង្គម ១៥%<br>- ភាសាកំណើត ១៥% | ភាសាខ្មែរ (L2) ៧០%<br>-ភាសាខ្មែរ ៤៥%<br>-គណិតវិទ្យា ១៥%<br>-សិក្សាសង្គម ១០% |
| ថ្នាក់ទី២ | ភាសាកំណើត (L1) ៦០%<br>-ភាសាកំណើត ២៥%<br>-សិក្សាសង្គម ៣៥% | ភាសាខ្មែរ (L2) ៤០%<br>-ភាសាខ្មែរ ២៥%<br>-គណិតវិទ្យា ១៥% |
| ថ្នាក់ទី១ | ភាសាកំណើត (L1) ៨០%<br>-ភាសាកំណើត ៣០%<br>-គណិតវិទ្យា ១៥%<br>-សិក្សាសង្គម ៣៥% | ភាសាខ្មែរ (L2) ២០%<br>-សម្រាប់តែការនិយាយប៉ុណ្ណោះ |
| **កម្រិតមត្តេយ្យសិក្សា** | | |
| ថ្នាក់មត្តេយ្យសិក្សា | កុមារអាយុ៣ឆ្នាំ និង៤ឆ្នាំ | កុមារអាយុ៥ឆ្នាំ |
| ឆមាសទី១ | និយាយភាសាកំណើត | ភាសាកំណើត |
| ឆមាសទី២ | និយាយភាសាកំណើត | ភាសាខ្មែរ២០នាទីក្នុងមួយថ្ងៃជារៀងរាល់ថ្ងៃ |

*តារាងទី១- គំរូអប់រំពហុភាសាសម្រាប់បឋមសិក្សា និងមត្តេយ្យសិក្សា*

### គំរូអប់រំពហុភាសាសម្រាប់ការអប់រំក្រៅប្រព័ន្ធ

| | | |
|---|---|---|
| ឆ្នាំទី៣ | ភាសាកំណើត (L1) ១០%<br>-បន្តការអាន និងសរសេរភាសាកំណើត | ភាសាខ្មែរ ៩០%<br>-រៀនអាន និងសរសេរភាសាខ្មែរឱ្យស្ទាត់ |
| ឆ្នាំទី២ | ភាសាកំណើត (L1) ៥០%<br>-រៀនអាន និងសរសេរភាសាកំណើតឱ្យស្ទាត់ | ភាសាខ្មែរ៥០%<br>-រៀនអាន និងសរសេរភាសាខ្មែរ |
| ឆ្នាំទី១ | ភាសាកំណើត (L1) ៩០%<br>-រៀនអាន និងសរសេរភាសាកំណើត | ភាសាខ្មែរ ១០%<br>-រៀននិយាយភាសាខ្មែរ |

*តារាងទី២- គំរូអប់រំពហុភាសាក្រៅប្រព័ន្ធប្រភពពីអង្គការICC*

## ១០.៨- ចំណោលចំនួនសាលារៀន គ្រូ និងសិស្សអប់រំពហុភាសា

### ❖ ការអនុវត្តកម្មវិធីអប់រំពហុភាសាសម្រាប់មត្តេយ្យសិក្សា

➕ ចំណោលចំនួនសាលាមត្តេយ្យសិក្សាអប់រំពហុភាសា

| ខេត្ត | ចំនួនថ្នាក់មត្តេយ្យសិក្សាអប់រំពហុភាសា | | | | | | ចំនួនថ្នាក់សរុប |
|---|---|---|---|---|---|---|---|
| | ២២-២៣ | ២៣-២៤ | ២៤-២៥ | ២៥-២៦ | ២៦-២៧ | ២៧-២៨ | |
| រតនគិរី | ៨៥ | ៩៤ | ៩៨ | ១០០ | ១០២ | ១០៤ | ១០៤ |
| មណ្ឌលគិរី | ១៥ | ១៥ | ១៥ | ១៥ | ១៥ | ១៥ | ១៥ |
| ស្ទឹងត្រែង | ១១ | ១១ | ១១ | ១១ | ១១ | ១១ | ១១ |
| ក្រចេះ | ១៥ | ១៥ | ១៥ | ១៥ | ១៥ | ១៥ | ១៥ |
| ព្រះវិហារ | ៧ | ៧ | ៧ | ៧ | ៧ | ៧ | ៧ |
| សរុប | ១៣៣ | ១៤២ | ១៤៦ | ១៤៨ | ១៥០ | ១៥២ | ១៥២ |

➕ ចំណោលចំនួនគ្រូមត្តេយ្យសិក្សាអប់រំពហុភាសា

| ខេត្ត | ចំនួនគ្រូមត្តេយ្យសិក្សាអប់រំពហុភាសា | | | | | | ចំនួនគ្រូសរុប |
|---|---|---|---|---|---|---|---|
| | ២២-២៣ | ២៣-២៤ | ២៤-២៥ | ២៥-២៦ | ២៦-២៧ | ២៧-២៨ | |
| រតនគិរី | ៨៥ | ៩៤ | ៩៨ | ១០០ | ១០២ | ១០៤ | ១០៤ |
| មណ្ឌលគិរី | ១៥ | ១៥ | ១៥ | ១៥ | ១៥ | ១៥ | ១៥ |
| ស្ទឹងត្រែង | ១១ | ១១ | ១១ | ១១ | ១១ | ១១ | ១១ |
| ក្រចេះ | ១៥ | ១៥ | ១៥ | ១៥ | ១៥ | ១៥ | ១៥ |
| ព្រះវិហារ | ៧ | ៧ | ៧ | ៧ | ៧ | ៧ | ៧ |
| សរុប | ១៣៣ | ១៤២ | ១៤៦ | ១៤៨ | ១៥០ | ១៥២ | ១៥២ |

➕ ចំណោលចំនួនសិស្សជនជាតិដើមភាគតិចចូលរៀននៅថ្នាក់មត្តេយ្យសិក្សាសម្រាប់កម្មវិធីអប់រំពហុភាសា

| ខេត្ត | ចំនួនសិស្សមត្តេយ្យសិក្សាអប់រំពហុភាសា | | | | | | ចំនួនសិស្សសរុប |
|---|---|---|---|---|---|---|---|
| | ២២-២៣ | ២៣-២៤ | ២៤-២៥ | ២៥-២៦ | ២៦-២៧ | ២៧-២៨ | |
| រតនគិរី | ១ ៥០៦ | ១ ៧២៣ | ១ ៨០០ | ១ ៨២០ | ១ ៨២០ | ១ ៨៤០ | ១ ៨៤០ |
| មណ្ឌលគិរី | ៤៣៥ | ៤៤៥ | ៤៣០ | ៤៤០ | ៤៤៥ | ៤៥០ | ៤៥០ |
| ស្ទឹងត្រែង | ១៧៣ | ១៩២ | ១៩០ | ១៩០ | ១៩០ | ១៩០ | ១៩០ |
| ក្រចេះ | ៣៤៥ | ៣១២ | ៣០០ | ៣០០ | ៣០០ | ៣០០ | ៣០០ |
| ព្រះវិហារ | ១៦៦ | ១៨៦ | ១៧០ | ១៧០ | ១៧០ | ១៨០ | ១៨០ |
| សរុប | ២ ៦២៥ | ២ ៨៥៨ | ២ ៨៩០ | ២ ៩២០ | ២ ៩២៥ | ២ ៩៦០ | ២ ៩៦០ |



### ❖ ការអនុវត្តកម្មវិធីអប់រំពហុភាសាសម្រាប់បឋមសិក្សា

➕ ចំណោលចំនួនសាលាបឋមសិក្សាអប់រំពហុភាសា

| ខេត្ត | ចំនួនសាលាបឋមសិក្សាអប់រំពហុភាសា | | | | | | ចំនួនសាលាសរុប |
|---|---|---|---|---|---|---|---|
| | ២២-២៣ | ២៣-២៤ | ២៤-២៥ | ២៥-២៦ | ២៦-២៧ | ២៧-២៨ | |
| រតនគិរី | ៤១ | ៤១ | ៤១ | ៤០ | ៣៥ | ៣៥ | ៣៥ |
| មណ្ឌលគិរី | ២៦ | ២៦ | ២៦ | ២០ | ២០ | ២០ | ២០ |
| ស្ទឹងត្រែង | ១១ | ១១ | ១១ | ១០ | ១០ | ១០ | ១០ |
| ក្រចេះ | ១៨ | ១៨ | ១៨ | ១៧ | ១៥ | ១៥ | ១៥ |
| សរុប | ៩៦ | ៩៦ | ៩៦ | ៨៧ | ៨០ | ៨០ | ៨០ |

***ការអនុវត្តកម្មវិធីអប់រំពហុភាសាមានការធ្លាក់ចុះព្រោះសាលាមួយចំនួនបានចាក់ចេញពីសម្រាប់ខេត្តរតនគិរីនឹងមានការកើនឡើងចំពោះសាលារៀនដែលអនុវត្តកម្មវិធីអប់រំពហុភាសាភាសាចារ៉ាយចំនួន៤សាលារៀនចាប់ពីឆ្នាំ ២០២០-២០២១*

➕ ចំណោលចំនួនគ្រូបឋមសិក្សាអប់រំពហុភាសា

| ខេត្ត | ចំនួនគ្រូបឋមសិក្សាអប់រំពហុភាសា | | | | | | ចំនួនគ្រូសរុប |
|---|---|---|---|---|---|---|---|
| | ២២-២៣ | ២៣-២៤ | ២៤-២៥ | ២៥-២៦ | ២៦-២៧ | ២៧-២៨ | |
| រតនគិរី | ៩១ | ៩៤ | ៩៨ | ៨០ | ៧៥ | ៧៥ | ៧៥ |
| មណ្ឌលគិរី | ៥៩ | ៥៩ | ៥៥ | ៥០ | ៤០ | ៤០ | ៤០ |
| ស្ទឹងត្រែង | ៣២ | ៣១ | ៣១ | ៣០ | ៣០ | ៣០ | ៣០ |
| ក្រចេះ | ៥៣ | ៥១ | ៥១ | ៥០ | ៥០ | ៥០ | ៥០ |
| សរុប | ២៥៣ | ២៣៥ | ២៣៥ | ២១០ | ១៩៥ | ១៩៥ | ១៩៥ |

➕ ចំណោលចំនួនសិស្សជនជាតិដើមភាគតិចចូលរៀននៅសាលាបឋមសិក្សាសម្រាប់កម្មវិធីអប់រំពហុភាសា

| ខេត្ត | ចំនួនសិស្សរៀននៅថ្នាក់អប់រំពហុភាសា | | | | | | ចំនួនសិស្សសរុប |
|---|---|---|---|---|---|---|---|
| | ២២-២៣ | ២៣-២៤ | ២៤-២៥ | ២៥-២៦ | ២៦-២៧ | ២៧-២៨ | |
| រតនគិរី | ២ ១៣៧ | ២ ០៣២ | ១ ៨៩៨ | ១ ៧០០ | ១ ៦០០ | ១ ៦០០ | ១ ៦០០ |
| មណ្ឌលគិរី | ១ ០៨៩ | ១ ០៨៤ | ១ ០៣២ | ៨០០ | ៧០០ | ៧០០ | ៧០០ |
| ស្ទឹងត្រែង | ៦២៩ | ៥៧០ | ៥៨២ | ៥០០ | ៥០០ | ៥០០ | ៥០០ |
| ក្រចេះ | ៨៤១ | ៧៩២ | ៧៤៨ | ៧០០ | ៧០០ | ៧០០ | ៧០០ |
| សរុប | ៤ ៦៩៦ | ៤ ៤៧៩ | ៤ ២៦១ | ៣ ៧០០ | ៣ ៥០០ | ៣ ៥០០ | ៣ ៥០០ |

## ❖ ការអនុវត្តកម្មវិធីអប់រំពហុភាសាសម្រាប់ថ្នាក់អក្ខរកម្ម

### ចំណោលចំនួនថ្នាក់អក្ខរកម្មអប់រំពហុភាសា

| ខេត្ត | ចំនួនថ្នាក់អក្ខរកម្មអប់រំពហុភាសា | | | | | | ចំនួនថ្នាក់សរុប |
|---|---|---|---|---|---|---|---|
| | ២២-២៣ | ២៣-២៤ | ២៤-២៥ | ២៥-២៦ | ២៦-២៧ | ២៧-២៨ | |
| រតនគិរី | ៨ | ៨ | ៨ | ៨ | ៨ | ៨ | ៨ |
| មណ្ឌលគិរី | ៤ | ៤ | ៤ | ៤ | ៤ | ៤ | ៤ |
| ស្ទឹងត្រែង | ៦ | ៦ | ៦ | ៦ | ៦ | ៦ | ៦ |
| ក្រចេះ | ៣ | ៣ | ៣ | ៣ | ៣ | ៣ | ៣ |
| **សរុប** | **២១** | **២១** | **២១** | **២១** | **២១** | **២១** | **២១** |

### ចំណោលចំនួនគ្រូអក្ខរកម្មអប់រំពហុភាសា

| ខេត្ត | ចំនួនគ្រូអក្ខរកម្មអប់រំពហុភាសា | | | | | | ចំនួនគ្រូសរុប |
|---|---|---|---|---|---|---|---|
| | ២២-២៣ | ២៣-២៤ | ២៤-២៥ | ២៥-២៦ | ២៦-២៧ | ២៧-២៨ | |
| រតនគិរី | ៨ | ៨ | ៨ | ៨ | ៨ | ៨ | ៨ |
| មណ្ឌលគិរី | ៤ | ៤ | ៤ | ៤ | ៤ | ៤ | ៤ |
| ស្ទឹងត្រែង | ៦ | ៦ | ៦ | ៦ | ៦ | ៦ | ៦ |
| ក្រចេះ | ៣ | ៣ | ៣ | ៣ | ៣ | ៣ | ៣ |
| **សរុប** | **២១** | **២១** | **២១** | **២១** | **២១** | **២១** | **២១** |

### ចំណោលចំនួនសិស្សជនជាតិដើមភាគតិចចូលរៀននៅថ្នាក់អក្ខរកម្មអប់រំពហុភាសា

| ខេត្ត | ចំនួនសិស្សអក្ខរកម្មអប់រំពហុភាសា | | | | | | ចំនួនសិស្សសរុប |
|---|---|---|---|---|---|---|---|
| | ២២-២៣ | ២៣-២៤ | ២៤-២៥ | ២៥-២៦ | ២៦-២៧ | ២៧-២៨ | |
| រតនគិរី | ១៦០ | ១៦០ | ១៦០ | ១៦០ | ១៦០ | ១៦០ | ១៦០ |
| មណ្ឌលគិរី | ៨០ | ៨០ | ៨០ | ៨០ | ៨០ | ៨០ | ៨០ |
| ស្ទឹងត្រែង | ១២០ | ១២០ | ១២០ | ១២០ | ១២០ | ១២០ | ១២០ |
| ក្រចេះ | ៦០ | ៦០ | ៦០ | ៦០ | ៦០ | ៦០ | ៦០ |
| **សរុប** | **៤២០** | **៤២០** | **៤២០** | **៤២០** | **៤២០** | **៤២០** | **៤២០** |

** * *ការអនុវត្តកម្មវិធីអក្ខរកម្មអប់រំពហុភាសាបានអនុវត្តដោយដៃគូអភិវឌ្ឍ ប៉ុន្តែពិបាកក្នុងការប្រមូលស្ថិតិមូលដ្ឋាន*